# កម្ពុជា

## ក្រោយសន្និសីទពិភពលោកលើកទី១ប្រឆាំង
## ការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ





រួមវិភាគទានក្នុងសន្និសីទពិភពលោកលើកទី២
ទីក្រុងយុកូហាម៉ា ប្រទេសជប៉ុន
ខែ ធ្នូ ឆ្នាំ ២០០១



មូលនិធិសិទ្ធិកុមារ (ម.ស.ក)
Child Rights Foundation (CRF)

**មូលនិធិសិទ្ធិកុមារ (មសក)** ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ផ្តោតលើកុមារ មិនរកផលកំរៃ មិនបំរើគណបក្សនយោបាយ ឬសាសនាណាមួយឡើយ។ **មសក** មានគោលបំណងប្រមូលផ្តុំធនធានចំរុះក្នុងស្រុក ការប្តេជ្ញា និងការអនុវត្តន៍ជាក់ស្តែង តាមរយៈការលើកស្ទួយសាមគ្គីភាព ការគោរពគ្នា និងការយោគយល់គ្នាក្នុងសង្គមខ្មែរ ឆ្ពោះទៅរកការធ្វើអោយប្រសើរឡើងនូវការរស់នៅ និងសិទ្ធិរបស់កុមារនៅក្នុងប្រទេសកម្ពុជា និងកុមារនៅក្នុងតំបន់។

ការងាររបស់ **មសក** គឺផ្តែកទាំងស្រុងលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដើម្បីធានាថាកុមារត្រូវបាន គោរព យកចិត្តទុកដាក់ថែទាំ និងការពារ។ **មសក** មានបេសកកម្មធំៗ៣គឺ: ទី១ធ្វើអោយមានការយល់ដឹងពីតំរូវការ និងសិទ្ធិរបស់កុមារតាមរយៈការផ្សព្វផ្សាយ និងការតស៊ូមតិនៅគ្រប់លំដាប់ថ្នាក់ ទី២ជួយរាជរដ្ឋាភិបាលក្នុងការអនុវត្តន៍ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនិងតាមដានការអនុវត្តន៍អនុសញ្ញានេះនៅក្នុងប្រទេសកម្ពុជា និងទី៣ លើកកំពស់ការចូលរួមនិងសំលេងរបស់កុមារនៅក្នុងសង្គម។


អាស័យដ្ឋាន:

ផ្ទះលេខ២៩អឺ១ មហាវិថីម៉ៅសេទុង សង្កាត់បឹងកេងកង១

ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទលេខ: ៨៥៥ ២៣ ២១១ ២២៣

អ៊ីម៉ែល: crf2000@forum.org.kh

# កម្ពុជា

## ក្រោយសន្និសីទពិភពលោកលើកទី១ប្រឆាំង ការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

រួមវិភាគទានក្នុងសន្និសីទពិភពលោកលើកទី២

នៅទីក្រុងយូកូហាម៉ា   ប្រទេសជប៉ុន

ថ្ងៃទី១៧-២០   ខែធ្នូ   ឆ្នាំ២០០១

# សេចក្តីថ្លែងអំណរគុណ

មូលនិធិសិទ្ធិកុមារ (ម.ស.ក.) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ :

* ឯកឧត្តម **គឹម សុខា** ប្រធានគណៈកម្មការការពារសិទ្ធិមនុស្សនិងទទួលពាក្យបណ្តឹងនៃព្រឹទ្ធសភា លោកជំទាវ **និន សាផុន** លេខាធិការគណៈកម្មការការពារសិទ្ធិមនុស្សនិងទទួលពាក្យបណ្តឹងនៃរដ្ឋសភា លោកជំទាវ **ម្ជូរ សុខហួរ** រដ្ឋមន្ត្រីក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ឯកឧត្តម **វង សូត** អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា លោក **លី ហ្សូគហ្ស៊ូ អាសីណល់** ប្រធានអង្គការយូនីសេហ្វ លោក **អ៊ូលើហ៍ ធាន់ ហាវ៉ុល** ប្រធានអង្គការន័រវេស៍សង្គ្រោះកុមារកម្ពុជា និងជាអ្នកសំរបសំរួលសម្ព័ន្ធអង្គការសង្គ្រោះកុមារ លោកស្រី **ប៊្រីជិត សូន័រ** មន្ត្រីកម្មវិធីនៃអង្គការយូនីសេហ្វ និងលោកស្រី **យ៉ាណែត អេស្សឺ** មន្ត្រីសំរបសំរួលកម្មវិធីជាតិប្រឆាំងអំពើជួញដូរស្ត្រី និងកុមារនៅតំបន់មេគង្គ ដែលបានផ្តល់នូវទស្សនៈល្អៗ និងពត៌មានផ្សេងៗទាក់ទងនឹងបញ្ហាជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

* ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងការបរទេស ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងអប់រំយុវជននិងកីឡា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ អ៊ិកផាតកម្ពុជា អង្គការយូនីសេហ្វ ឧត្តមស្នងការ អ.ស.ប.ទទួលបន្ទុកសិទ្ធិមនុស្សការិយាល័យប្រចាំប្រទេសកម្ពុជា កម្មវិធីជាតិប្រឆាំងអំពើជួញដូរស្ត្រី និងកុមារនៅតំបន់មេគង្គ អង្គការពលកម្មអន្តរជាតិ អង្គការអន្តរជាតិទេសន្តរប្រវេសន៍ សម្ព័ន្ធអង្គការសង្គ្រោះកុមារ អង្គការលីកាដូ មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ អង្គការស្តើប អង្គការទស្សនៈពិភពលោក មជ្ឈមណ្ឌលកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ មជ្ឈមណ្ឌលថែទាំសុខភាពកុមារ ការិយាល័យកាតូលិកអន្តរជាតិសំរាប់កុមារ អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា អង្គការសិទ្ធិមនុស្សវីជីលែន សមាគមកុមារនិងក្តីស្រលាញ់ គណៈកម្មាធិការកុមារ ក្រុមជំនួយកុមារដើម្បីការរួបរួមនិងការចូលរួម ក្រុមអភិវឌ្ឍន៍យុវជនកម្ពុជា ក្លឹបនារីដើម្បីសន្តិភាព ក្លឹបយុវជនខ្មែរនិងការអភិវឌ្ឍន៍សង្គម គណៈកម្មាធិការប្រតិបត្តិនិស្សិតនៃកម្មវិធីអភិវឌ្ឍន៍យុវជនកម្ពុជា សមាគមសង្គ្រោះនិងស្តារនីតិសម្បទាយុវនារី និងមូលនិធិអាស៊ី ដែលបានផ្តល់ការគាំទ្រនិងបញ្ជូនតំណាងព្រមទាំងកុមាររងគ្រោះ មកធ្វើបទឧទ្ទេសនាម និងចូលរួមយ៉ាងសកម្មក្នុងសិក្ខាសាលារយៈពេល៣ថ្ងៃស្តីពីការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (ជ.ក.ផ.ក.)ទាំងពីរលើក។

* អង្គការយូនីសេហ្វ កម្មវិធីជាតិប្រឆាំងអំពើជួញដូរស្ត្រី និងកុមារនៅតំបន់មេគង្គ និងអង្គការន័រវេស៊្សសង្គ្រោះកុមារកម្ពុជា ដែលបានជួយគាំទ្រផ្នែកហិរញ្ញវត្ថុដល់គំរោងការនេះ។

**ម.ស.ក.** សូមទទួលស្គាល់ជាពិសេសចំពោះសិក្ខាសាលាថ្នាក់ជាតិ និងរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ របាយការណ៍នេះ និងរបាយការណ៍របស់រដ្ឋាភិបាល មានលក្ខណៈបំពេញអោយគ្នាទៅវិញទៅមក និងតំណាងនូវកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួតសំដៅបំរើអោយផលប្រយោជន៍កុមារ និងយុវជនកម្ពុជា។

សមិទ្ធិផលដ៏សំខាន់នេះមិនអាចលេចចេញជារូបរាងបានឡើយ ប្រសិនពុំមានការគាំទ្រ និងការរួមចំណែកដ៏ថ្លៃថ្លាពីសំណាក់លោកជំទាវ ឯកឧត្តម លោក លោកស្រី យុវជន និងកុមារាកុមារីទាំងអស់នោះទេ។

| ទំព័រ | មាតិកា |
|---|---|
| ១១ | ១. សេចក្តីផ្តើម |
| ១៥ | ២. ស្ថានភាពទូទៅនៃការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា |
| ២១ | ៣. សកម្មភាពដែលរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលបានអនុវត្ត |
| ២៩ | ៤. ការលំបាកនិងឧបសគ្គចំពោះមុខ |
| ៣៤ | ៥. ក្តីស្រមៃនិងសំណូមពររបស់កុមារនិងយុវជន |
| ៤៥ | ៦. អនុសាសន៍សំរាប់អនុវត្តបន្ត |

# ទិន្នន័យទូទៅនៃប្រទេសកម្ពុជា

| | |
|---|---|
| - ផ្ទៃដី | ១៨១.០៣៥ គ.មក្រឡា |
| - ចំនួនខេត្តក្រុង | ២៤ |
| - ប្រជាជន | ១៣.០៩៩.០០០នាក់ |
| - កុមារអាយុក្រោម១៥ឆ្នាំ | ៤២,៨០% |
| - កុមារអាយុក្រោម១៨ឆ្នាំ | ៥១% |
| - អត្រាកំនើនប្រជាជនប្រចាំឆ្នាំ | ២,៦០% |
| - អត្រាមរណៈកុមារក្រោម១ឆ្នាំ | ៩៥ក្នុងចំណោម១.០០០នាក់ |
| - អត្រាមរណៈកុមារអាយុក្រោម៥ឆ្នាំ | ១២៥ក្នុងចំណោម១.០០០នាក់ |
| - កុមារខ្វះជីវជាតិអាយុក្រោម៥ឆ្នាំ | ៥០% |
| - ផលទុនក្នុងស្រុកសរុបសំរាប់ប្រជាជន១នាក់ | ២៨៦ដុល្លារអាមេរិក |
| - អត្រាអក្ខរជន (អាយុ១៥ឆ្នាំឡើង) | ៦៧,៣% |

(ប្រភព : អាំងឌីកាទ័រអប់រំឆ្នាំ១៩៩៩-២០០ ការវិនិយោគជាមួយ
កុមារ២០០១-២០០៥ យូនីសេហ្វ)

# ១

# សេចក្តីផ្តើម

## ការប្តេជ្ញាចិត្តនិងក្រុងស្តុកខុលម៍

- ផ្តល់អាទិភាពខ្ពស់ដល់វិធានការប្រឆាំងការជ.ក.ផ.ក. និងរៀបចំអោយមានធនធានគ្រប់គ្រាន់សំរាប់ការងារនេះ ។
- បង្កើនកិច្ចសហប្រតិបត្តិការអោយកាន់តែខ្លាំងឡើងរវាងរដ្ឋនិងស្ថាប័នទាំងអស់ក្នុងសង្គមជាតិដើម្បីការពារកុមារពីការធ្លាក់ខ្លួនទៅក្នុងជំនួញផ្លូវភេទ និងពង្រឹងតួនាទីក្រុមគ្រួសារក្នុងការការពារកុមារប្រឆាំងការជ.ក.ផ.ក ។
- ផ្តន្ទាទោសឧក្រិដ្ឋដល់ការជ.ក.ផ.ក. និងទំរង់កេងប្រវ័ញ្ចផ្លូវភេទផ្សេងៗទៀត ។ ថ្កោលទោសជនល្មើសទាំងអស់ដែលពាក់ព័ន្ធក្នុងអំពើនោះ ទាំងនៅក្នុងនិងក្រៅប្រទេស ដោយត្រូវធានាថាកុមាររងគ្រោះមិនត្រូវបានផ្តន្ទាទោសទេ ។
- ពិនិត្យឡើងវិញ និងកែសំរួលច្បាប់ គោលនយោបាយ កម្មវិធីនិងការអនុវត្តន៏ ដើម្បីលុបបំបាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។
- ពង្រឹងច្បាប់ គោលនយោបាយ និងកម្មវិធីដើម្បីការពារកុមារពីការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទ និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរអនុវត្តច្បាប់ ។
- ជំរុញអោយមានការអនុម័ត ការអនុវត្តន៏ និងការផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងកម្មវិធីដែលគាំទ្រដោយយន្តការតំបន់ ជាតិ និងមូលដ្ឋាន ។
- អភិវឌ្ឍនិងអនុវត្តផែនការយល់ដឹងអំពីសមភាពរវាងបុរសនិងស្ត្រី និងកម្មវិធីនានាដើម្បីទប់ស្កាត់ការជ.ក.ផ.ក. ។
- បង្កើតបរិយាកាសមួយតាមរយៈការអប់រំ ការបំផុសចលនាសង្គម និងសកម្មភាពអភិវឌ្ឍន៏នានាដើម្បីធានាថាមាតាបិតា និងអ្នកដែលទទួលខុសត្រូវស្របច្បាប់ចំពោះកុមារអាចមានលទ្ធភាពបំពេញសិទ្ធិកាតព្វកិច្ច និងការទទួលខុសត្រូវរបស់គេ ដើម្បីការពារកុមារពីការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ ។
- បំផុសចលនាដៃគូជាអ្នកនយោបាយ និងដៃគូរួមការងារឯទៀតទាំងសហគមន៏ជាតិ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អោយជួយបណ្តាប្រទេសនានាក្នុងការលុបបំបាត់អំពើជ.ក.ផ.ក. ។
- បង្កើនតួនាទីចូលរួមរបស់ប្រជាពលរដ្ឋរួមទាំងកុមារផងដែរ អោយជួយទប់ស្កាត់និងលុបបំបាត់ការជ.ក.ផ.ក. ។



# សេចក្តីផ្តើម

កូនសៀវភៅក្រោមចំណងជើង **"កម្ពុជាក្រោយសន្និសីទពិភពលោកលើកទី១ប្រឆាំងការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ"** គឺជាការរួមចំណែករបស់សង្គមស៊ីវិលក្នុងការតាមដានការអនុវត្តន៍ផែនការសកម្មភាពរបស់សន្និសីទពិភពលោកលើកទី១ និងផែនការជាតិ៥ឆ្នាំប្រឆាំងការ ជ.ក.ផ.ក.និងដើម្បីរួមវិភាគទានជាមួយសន្និសីទពិភពលោកលើកទី២ ។

ស្ថានភាពជ.ក.ផ.ក.នៅក្នុងប្រទេសកម្ពុជា សកម្មភាពអនុវត្តកន្លងមក ការលំបាកនិងឧបសគ្គចំពោះមុខ ក្តីស្រមៃនិងសំណូមពររបស់កុមារនិងយុវជន ច្បាប់និងគោលនយោបាយពាក់ពន្ធ័ បទពិសោធន៍ល្អៗ ករណីកុមាររងគ្រោះ ព្រមទាំងអនុសាសន៍សំខាន់ៗសំរាប់អនុវត្តបន្ត ត្រូវបានលើកឡើងនៅក្នុងសៀវភៅនេះ ។

ខ្លឹមសារទាំងស្រុងនៃសៀវភៅ គឺបានមកពីលទ្ធផលនៃការពិភាក្សាក្នុងវគ្គសិក្ខាសាលារយៈពេល៣ថ្ងៃស្តីពីការ ជ.ក.ផ.ក.ចំនួនពីរលើកដាច់ដោយឡែកពីគ្នា គឺមួយរៀបចំសំរាប់កុមារនិងយុវជន និងមួយទៀតសំរាប់តំណាងអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងស្ថាប័នរដ្ឋពាក់ពន្ធ័ ព្រមទាំងបានមកពីការសម្ភាសន៍ជាមួយមនុស្សសំខាន់ៗនិងកុមាររងគ្រោះ និងការសិក្សាស្រាវជ្រាវឯកសារដែលមានស្រាប់ ។

កូនសៀវភៅនេះនឹងត្រូវចែកជូនដល់ស្ថាប័នព្រឹទ្ធសភា រដ្ឋសភាជាតិ រាជរដ្ឋាភិបាល ស្ថានទូត អង្គការជាតិ អង្គការអន្តរជាតិ និងក្នុងឱកាសសន្និសីទពិភពលោកលើកទី២ ។

សូមរំលឹកថាសន្និសីទពិភពលោកលើកទី១ប្រឆាំងការជ.ក.ផ.ក.បានប្រារព្ធឡើងកាលពីខែសីហា ឆ្នាំ១៩៩៦ នៅទីក្រុងស្តុកខុលម៍ ប្រទេសស៊ុយអែដ ។ ប្រតិភូតំណាងប្រទេសចំនួន១២២ ក្នុងនោះមានប្រទេសកម្ពុជាផងដែរ បានអញ្ជើញចូលរួម ហើយបានអនុម័តជាឯកច្ឆន្ទលើសេចក្តីប្រកាស និងផែនការសកម្មភាពនៃអង្គសន្និសីទ ដើម្បីចាត់វិធានការការពារកុមារពីការធ្វើអាជីវកម្មផ្លូវភេទ ទេសចរណ៍ផ្លូវភេទ ការប្រើប្រាស់កុមារក្នុងការផលិតចេញជាសំភារៈផ្អែកកាមសាស្រ្តអាសគ្រាម និងការជួញដូរ ព្រមទាំងបានឯកភាពបង្កើតភ្នាក់ងារបង្គោល (Focal points) ប្រចាំប្រទេសនិងបង្កើតផែនការជាតិប្រឆាំងបញ្ហានេះនៅឆ្នាំ២០០០ ។

ខែធ្នូឆ្នាំ២០០១នេះ សន្និសីទពិភពលោកលើកទី២នឹងប្រព្រឹត្តទៅនៅទីក្រុងយូកូហាម៉ា ប្រទេសជប៉ុន ក្នុងគោលបំណងពង្រឹងការប្តេជ្ញាចិត្តផ្នែកនយោបាយក្នុងការអនុវត្តន៍ផែនការសកម្មភាពដែលបានអនុម័តក្នុងសន្និសីទលើកទី១ ត្រួតពិនិត្យឡើងវិញនូវភាពរីកចំរើននៃការអនុវត្តន៍ផែនការនេះ ចែករំលែកនូវបទពិសោធន៍ និងការអនុវត្តន៍ល្អៗ ស្វែងរកការខ្វះចន្លោះក្នុងការប្រយុទ្ធប្រឆាំងនឹងការ ជ.ក.ផ.ក. និងពង្រឹងដំណើរការតាមដាន

បន្តពីសន្និសីទ។ តំណាងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងបណ្តាភ្នាក់ងារ និងមនុស្សសំខាន់ៗទូទាំងពិភពលោកនឹងត្រូវអញ្ជើញចូលរួមក្នុងព្រឹត្តិការណ៍ដ៏សំខាន់នេះ។

សង្ឃឹមថា កូនសៀវភៅនេះនឹងក្លាយជាឧបករណ៍យ៉ាងសំខាន់មួយសំរាប់ធ្វើការទាក់ទាញការគាំទ្រការធ្វើផែនការ និងការជំរុញការអនុវត្តន៍ផែនការជាតិ៥ឆ្នាំអោយកាន់តែមានប្រសិទ្ធភាព ឈានទៅលុបបំបាត់ការជ.ក.ផ.ក.នៅក្នុងប្រទេសកម្ពុជា។

# ២

# ស្ថានភាពទូទៅនៃការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅកម្ពុជា

## ទិន្នន័យពាក់ព័ន្ធការជ.ក.ផ.ក.

| អំឡុងពេល | របប/សម័យកាល | ស្ថានភាពពេស្យាចារ |
|---|---|---|
| មុនឆ្នាំ១៩៧០ | ព្រះរាជាណាចក្រកម្ពុជា | មានតែមិនទាន់រីករាលដាល |
| ១៩៧០–១៩៧៥ | សាធារណរដ្ឋខ្មែរ | កើនឡើងដោយសារសង្គ្រាមនៅវៀតណាម |
| ១៩៧៥–១៩៧៩ | កម្ពុជាប្រជាធិបតេយ្យ | ហាមឃាត់ |
| ១៩៧៩–១៩៨៩ | សាធារណរដ្ឋប្រជាមានិតកម្ពុជា | មានតែឃុំគ្រងយ៉ាងម៉ឺងម៉ាត់ |
| ១៩៨៩–១៩៩៣ | រដ្ឋកម្ពុជា | |
| ១៩៩០ | | ១.៥០០នាក់នៅភ្នំពេញ |
| ១៩៩១ | អ៊ុនតាក់ | ៦.០០០នាក់ |
| ១៩៩២ | អ៊ុនតាក់ | ២០.០០០នាក់ |
| ១៩៩៣–បច្ចុប្បន្ន | ព្រះរាជាណាចក្រកម្ពុជា | |
| ១៩៩៥ | ក្រោយអ៊ុនតាក់ | ១៧.០០០នាក់ |
| ២០០១ | | ១៧.០០០នាក់នៅភ្នំពេញ ៣០%អាយុក្រោម១៨ឆ្នាំ ទូទាំងប្រទេសមាន៨០.០០០ទៅ១០០.០០០នាក់ |

(ប្រភព: របាយការណ៍ស្តីពីការអភិវឌ្ឍន៍មនុស្សនៅកម្ពុជាឆ្នាំ២០០០របស់ក្រសួងផែនការ និងផែនការជាតិ៥ឆ្នាំប្រឆាំងការជ.ក.ផ.ក.)

- មានកុមារនិងស្ត្រីកម្ពុជាចំនួនពី៤០០ ទៅ៨០០នាក់ ត្រូវបានគេជួញដូរអោយទៅបំរើផ្លូវភេទនៅក្រៅប្រទេសជារៀងរាល់ខែ ។

(ប្រភព: CCC)

- ឆ្នាំ២០០១មានកុមារ ២.៦១៤នាក់ ឆ្លងមេរោគអេដស៍
- ដើមឆ្នាំ២០០១មានកុមារ ២.៥៩២នាក់ស្លាប់ដោយសារអេដស៍

(ប្រភព: អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍)



# ស្ថានភាពទូទៅនៃការជួញដូរនិងកេងប្រវ័ញ្ច ផ្លូវភេទលើកុមារនៅកម្ពុជា

ការជ.ក.ផ.ក.គឺជាក្តីកង្វល់របស់ពិភពលោកទាំងមូល ដោយសារបទឧក្រិដ្ឋអមនុស្សធម៌នេះបាននិងកំពុងរាតត្បាតទាំងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ ហើយនិងកំពុងបំផ្លិចបំផ្លាញធនធានមនុស្សជាពិសេសកុមារ គ្រួសារនិងសហគមន៍ ដែលបញ្ហានេះពុំគួរត្រូវបណ្តែតបណ្តោយអោយរីករាលដាលតទៅទៀតបានឡើយ។

ដោយឡែកនៅកម្ពុជាអំពើពេស្យាចារបានកើតមានឡើងតាំងពីយូរយារណាស់មកហើយ ប៉ុន្តែនៅក្រោមរបបខ្មែរក្រហមអំពើនេះត្រូវហាមឃាត់ដោយកំលាំងប្រដាប់អាវុធ។ បន្ទាប់ពីឆ្នាំ១៩៧៩មកនៅក្នុងរបបរដ្ឋកម្ពុជាអំពើពេស្យាចារត្រូវបានគេឃុំគ្រងយ៉ាងតឹងតែងជាទីបំផុត។ រហូតមកដល់ទសវត្សឆ្នាំ១៩៩០ បន្ទាប់ពីការបើកព្រំដែន និងសេដ្ឋកិច្ចទីផ្សារសេរីមក ការជួញដូរស្ត្រីនិងកុមារបំរើជាពេស្យាចារបានក្លាយជាបញ្ហាដ៏ក្តៅគគុកមួយគួរអោយព្រួយបារម្ភ ហើយបញ្ហានេះនៅតែបន្តកើតមាន និងរីកដុះដាលជាលំដាប់។ តាមរបាយការណ៍ស្តីពីការអភិវឌ្ឍន៍មនុស្សនៅកម្ពុជាឆ្នាំ២០០០របស់ក្រសួងផែនការ បានប៉ាន់ស្មានថាអ្នករកស៊ីផ្លូវភេទនៅកម្ពុជាមានចំនួនពី ៨០.០០០ទៅ១០០.០០០នាក់ ដោយឡែកនៅភ្នំពេញមានចំនួន១៧.០០០នាក់ ដែលក្នុងនោះ៣០%មានអាយុក្រោម១៨ឆ្នាំ។ នៅទូទាំងប្រទេស មានផ្ទះបនមិនតិចជាង៣០០កន្លែងទេ ទន្ទឹមនឹងនេះក៏មានការកើនឡើងនូវបណ្តាផ្ទះសំណាក់ ក្លិបកំសាន្ត ហាងកោសខ្យល់ ម៉ាស្សា ខារ៉ាអូខេ ហាងកាហ្វេ ហាងកែសម្ផស្ស ភោជនីយដ្ឋាន រង្គសាល។ល។ ទីកន្លែងទាំងនេះ ខ្លះបើកជាចំហ ខ្លះបើកជារបៀបលួចលាក់ដែលក្នុងនោះ កន្លែងខ្លះមានបណ្តាញសំងាត់រកស៊ីលក់កុមារីវ័យក្មេងៗនៅព្រហ្មចារីយ៍។

តាមរបាយការណ៍របស់ក្រសួងមហាផ្ទៃឆ្នាំ១៩៩៩ក៏ដូចជារបាយការណ៍អង្កេតការណ៍របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM)ឆ្នាំ១៩៩៨–៩៩ បានអោយដឹងថាមានការនាំស្ត្រីជនជាតិវៀតណាមមកកម្ពុជាដើម្បីប្រកបរបររកស៊ីផ្លូវភេទ ហើយគេក៏ឃើញមានការនាំស្ត្រីភេទចេញពីកម្ពុជាទៅកាន់ប្រទេសក្រៅដើម្បីធ្វើជាពេស្យាចារដែរ ដូចជាទៅប្រទេសថៃ ហុងកុង ម៉ាឡេស៊ី។ល។ ផ្អែកតាមឯកសាររបស់ប្រទេសកម្ពុជាសំរាប់ការចូលរួមសន្និសីទស្តីអំពីការផ្តួចផ្តើមគំនិតប្រឆាំងការជួញដូរស្ត្រីនិងកុមារនៃតំបន់អាស៊ីឆ្នាំ២០០០ បានបង្ហាញថាមានប្រជាជនកម្ពុជា៨៨.០០០នាក់រស់នៅក្នុងប្រទេសថៃ និង៧.០០០នាក់រស់នៅក្នុងប្រទេសវៀតណាមដោយគ្មានលិខិតស្នាមស្របច្បាប់។ ក្នុងឆ្នាំ២០០១ជារៀងរាល់ខែមាន

ប្រជាពលរដ្ឋកម្ពុជា ប្រមាណជា១.៦៥០នាក់ ត្រូវបានគេបញ្ជូនមកពីប្រទេសថៃវិញក្នុងនោះ ប្រហែល៥០%ជាស្ត្រីនិងកុមារ (មជ្ឈមណ្ឌលកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ)។

អំពើរំលោភសេពសន្ថវៈលើកុមារ ក៏ជាបញ្ហាដ៏គួរអោយព្រួយបារម្ភមួយដែរក្នុងប្រទេសកម្ពុជា។ យ៉ាងហោចណាស់មានកុមារពី៥ទៅ៦នាក់ជារៀងរាល់ខែ ត្រូវទទួលរងគ្រោះដោយសារបញ្ហានេះហើយប្រហែល៩០%នៃករណីទាំងនេះមិនត្រូវបានបញ្ជូនទៅតុលាការទេ ប៉ុន្តែត្រូវបានគេដោះស្រាយតាមរយៈការសំរុះសំរួល ឬការសងជំងឺចិត្ត (សេចក្ដីថ្លែងការណ៍របស់គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារទៅគណៈកម្មាធិការអង្គការសហប្រជាជាតិដើម្បីសិទ្ធិកុមារឆ្នាំ២០០០)។

មានប្រជាជនកម្ពុជាប្រមាណ៣៧%រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ដែលត្រូវបានទទួលស្គាល់ថាជាកត្តាចំបងក្នុងការជំរុញអោយកុមារចាកចេញឆ្ងាយពីឪពុកម្ដាយ ក្រុមគ្រួសារដើម្បីរកកំរៃផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ។ ក្នុងការស្វែងរកមុខរបរដ៏លំបាក និងក្នុងសមត្ថភាពរាងកាយ និងគំនិតដ៏ក្មេងខ្ចី កុមារត្រូវប្រឈមមុខនឹងបញ្ហាជាច្រើន។ ពេលខ្លះត្រូវរងគ្រោះដោយសារចាញ់ល្បិចគេ ដូចជាការសន្យារកការងារអោយធ្វើ សង្សារបោកយកទៅលក់ ការបង្ខិតបង្ខំរំលោភលើរាងកាយពីជនខិលខូចមួយចំនួន។ មានកុមារខ្លះទៀតធ្លាក់ខ្លួនទៅក្នុងអំពើពេស្យាចារដោយសារមានអំពើហិង្សាក្នុងគ្រួសារ គ្រួសារបែកបាក់ កំព្រា ឬឪពុកម្ដាយយកទៅលក់ដើម្បីដោះបំណុលឬយកប្រាក់ទៅលេងល្បែងស៊ីសង ខ្លះទៀតត្រូវរងគ្រោះដោយសារអាពាហ៍ពិពាហ៍ក្លែងក្លាយហើយត្រូវបានគេនាំទៅលក់នៅបរទេស។

ទន្ទឹមនឹងភាពក្រីក្រ ប្រជាជនកម្ពុជាមួយចំនួនជាពិសេសនៅតាមជនបទដាច់ស្រយាលស្ថិតក្នុងភាពអវិជ្ជា ដែលធ្វើអោយពួកគេងាយរងគ្រោះ។ រីឯការផ្សព្វផ្សាយពត៌មានផ្សេងៗដើម្បីពង្រីកចំណេះដឹងដល់ប្រជាជនក៏នៅមានកំរិត ពោលគឺពុំទាន់ធ្វើបានទូលំទូលាយនៅទូទាំងប្រទេសនៅឡើយ។ ផ្ទុយទៅវិញការហូរចូលដ៏គំហុកនៃវប្បធម៌បរទេស តាមរយៈកម្មវិធីទូរទស្សន៍ ភាពយន្ត វីដេអូនិងសិល្បៈផ្សេងៗ ដែលបង្ហាញពីអំពើហិង្សាភាពសាហាវឃោរឃៅ អំពើអាសអាភាសមានលក្ខណៈផ្ទុយពីវប្បធម៌ ប្រពៃណីជាតិខ្មែរ គឺជាការអប់រំបិទមុខមួយរុញច្រានអោយយុវវ័យភ្លើតភ្លើនភ្លេចស្មារតី ធ្លាក់ខ្លួនក្នុងអំពើពាលាអាវ៉ាសែនិងខូចអនាគត។

ថ្វីត្បិតតែប្រទេសកម្ពុជាមានច្បាប់មួយចំនួនការពារកុមារ ដូចជាច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្សនិងអំពើធ្វើអាជីវកម្មលើមនុស្ស ក៏ប៉ុន្តែការអនុវត្តន៍នៅពុំទាន់មានប្រសិទ្ធភាពនៅឡើយ ហើយការផ្សព្វផ្សាយអំពីច្បាប់ដែលមានស្រាប់ក៏ពុំទាន់បានទូលំទូលាយទៅដល់មូលដ្ឋានដាច់ស្រយាលផងដែរ។ មានករណីខ្លះមិនត្រូវបានដោះស្រាយសមស្របទៅតាមនីតិវិធីទេដោយសារមានមន្ត្រីអនុវត្តច្បាប់មួយចំនួនប្រព្រឹត្តអំពើពុករលួយ។



ក្រៅពីជនបរទេសមួយចំនួនជាអ្នកទេសចរណ៍ ឬជាអ្នកធ្វើការក្នុងអង្គការក្រៅរដ្ឋាភិបាល និងអ្នកជំនួញអតិថិជនដែលត្រូវការសេវាផ្លូវភេទភាគច្រើនគឺជាជនជាតិខ្មែរ។ មិនមែនមានតែកុមារីទេដែលទទួលរងគ្រោះបែបនេះ ប៉ុន្តែកុមារាក៏ជាមុខសញ្ញាដែលជនបរទេសខ្លះ និយមជ្រើសរើសដើម្បីបំរើតំរូវការផ្លូវភេទរបស់ខ្លួនឬថតរូបអាសអាភាសសំរាប់ធ្វើអាជីវកម្ម ផ្សព្វផ្សាយតាមរយៈទស្សនាវដ្តី ប្រព័ន្ធអ៊ីនធើណិតក្នុងបំណងទាក់ទាញអតិថិជនដទៃទៀត។

កត្តាទាំងនេះរួមចំណែកធ្វើអោយកម្ពុជាក្លាយទៅជាគោលដៅសំរាប់ការជួញដូរ និងទេសចរណ៍ផ្លូវភេទ។ មានកុមារាកុមារីមិនតិចទេដែលរងគ្រោះដោយសារអំពើទាំងនេះ ដែលជាហេតុធ្វើអោយកុមារបាត់បង់ឱកាសទទួលការអប់រំរៀនសូត្រ ការអភិវឌ្ឍន៍បញ្ញាស្មារតី និងរាងកាយទទួលរងនូវការរើសអើងពីសហគមន៍ ហើយកុមាររងគ្រោះជាច្រើនត្រូវឆ្លងជំងឺកាមរោគផ្សេងៗពិសេសជំងឺអេដស៍ដែលទាំងអស់នេះជាកត្តាបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរចំពោះសង្គមជាតិទាំងបច្ចុប្បន្ននិងអនាគត។

## ការជួញដូរមនុស្សនៅអនុតំបន់មេគង្គ




Source: UNIFEM (1998)

ជារៀងរាល់ឆ្នាំមនុស្សប្រមាណ២០០.០០០នាក់នៅអាស៊ីត្រូវគេជួញដូរនិងបង្ខំអោយធ្វើជាអ្នករកស៊ីផ្លូវភេទនិងពលករ។ ក្នុងចំណោមនេះមាន៣៥.០០០–៤០.០០០ជាយុវវ័យនិងកុមារ។

(បណ្ឌិត សៃស៊ុរី ជុធីគុល)

## ឯកសារគតិយុត្តិអន្តរជាតិពាក់ព័ន្ធការជ.ក.ផ.ក.

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ មាត្រា៣៤ និង៣៥។
- អនុសញ្ញាILOលេខ១៨២ស្តីពីការហាមឃាត់និងចាត់វិធានការជាបន្ទាន់ដើម្បីលុបបំបាត់ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។
- អនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនារីភេទ (CEDAW) មាត្រា៦។
- សេចក្តីប្រកាសនិងផែនការសកម្មភាពទីក្រុងស្តុកខុលម៍ ១៩៩៦។
- ពិធីសារបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ស្តីពីការជួញដូរកុមារ ពេស្យាចារកុមារ និងអំពើកាមសាស្ត្រលើកុមារ។
- ពិធីសារបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងប្រទេស ស្តីពីការទប់ស្កាត់និងការដាក់ទណ្ឌកម្មទៅលើការជួញដូរមនុស្សជាពិសេសទៅលើស្ត្រី និងកុមារ។

# ៣

# សកម្មភាពដែលរដ្ឋាភិបាលនិង
# អង្គការមិនមែនរដ្ឋាភិបាលបាន
# អនុវត្ត

## ឯកសារ បទបញ្ជា និងច្បាប់កម្ពុជានានាដែលពាក់ព័ន្ធនឹងការជ.ក.ផ.ក.

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣) មាត្រា៤៦ និង៤៨។
- បញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល (ច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ ឆ្នាំ១៩៩២) មាត្រា៣៥ ៣៦ ៤១ និង៤២(៣)។
- ច្បាប់ស្តីពីការបង្ក្រាបភេរវកម្ម (ឆ្នាំ១៩៩២) មាត្រា២។
- ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្សនិងអំពើធ្វើអាជីវកម្មលើមនុស្ស (ឆ្នាំ១៩៩៦) មាត្រា៤ និងមាត្រា៨។
- ក្រិតរបស់ក្រសួងយុត្តិធម៌ស្តីពីការបង្កើតគណៈកម្មាធិការជាតិផ្នែកសិទ្ធិកុមារនិងគណៈកម្មាធិការការពារប្រឆំាងនឹងការជិះជាន់ទៅលើកុមារ (ឆ្នាំ១៩៩៧)។
- អនុក្រិតលេខ៣២សជរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីការរៀបចំនិងគ្រប់គ្រងកុននិងវីដេអូ (ឆ្នាំ១៩៨៩)។
- សេចក្តីសំរេចលេខ១៤ ស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួងដើម្បីបង្ក្រាបការធ្វើអាជីវកម្ម ការផលិត និងលក់កាស្សែតវីដេអូអាសអាភាសនៅទីក្រុងភ្នំពេញ (ឆ្នាំ១៩៩៦)។
- គណៈកម្មាធិការសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹងនៃរដ្ឋសភាជាតិ។ របាយការណ៍បញ្ហាជិះជាន់ និងការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា (ឆ្នាំ១៩៩៧)។
- ផែនការជាតិប្រឆំាងការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (២០០០-២០០៤)។
- សេចក្តីប្រកាសស្តីពីវិធានការចាត់តាំងអនុវត្តផែនការជាតិ៥ឆ្នាំប្រឆាំងការជ.ក.ផ.ក. (មេសា ២០០០)។



# សកម្មភាពដែលរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលបានអនុវត្ត

បន្ទាប់ពីសន្និសីទពិភពលោកឆ្នាំ១៩៩៦មក ទាំងរាជរដ្ឋាភិបាលក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការបង្កើត និងអនុវត្តន៍គោលនយោបាយ និងកម្មវិធីនានាសំដៅទប់ស្កាត់ និងលុបបំបាត់ការជ.ក.ផ.ក.នៅកម្ពុជា ក្នុងនោះកម្មវិធីនិងសកម្មភាពចំបងៗរួមមាន :

## ផ្នែកគោលនយោបាយ

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្លាំងលើការបង្កើតគោលនយោបាយដោយដាក់ចេញនូវច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្សនិងអំពើធ្វើអាជីវកម្មលើមនុស្ស ច្បាប់ស្តីពីការត្រួតពិនិត្យលើគ្រឿងញៀន ច្បាប់ការងារ។ល។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលបានចេញអនុក្រិត សារាចរ និងសេចក្តីសំរេចមួយចំនួនដែលទាក់ទងទៅនឹងការហាមឃាត់ការលក់ ការជួល ឬការបញ្ចាំងវីដេអូអាសអាភាស និងហាមឃាត់ស្ថានីយ៍ទូរទស្សន៍ផ្សេងៗក្នុងការបញ្ចាំងខ្សែភាពយន្តអាសអាភាស អំពើហិង្សា និងមិនអនុញ្ញាតអោយកុមារធ្វើសកម្មភាពក្នុងកម្មវិធីដែលគ្មានការអប់រំហើយដែលអាចប៉ះពាល់ដល់ខ្លួនគេ។

ជាពិសេសរាជរដ្ឋាភិបាលបានបង្កើតផែនការជាតិ៥ឆ្នាំប្រឆាំងការជ.ក.ផ.ក.ដោយមានការចូលរួមផ្តល់យោបល់ក្នុងការធ្វើព្រាងពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិនានាផងដែរ។ ដើម្បីតាមដានការអនុវត្តន៍ផែនការនេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានបង្កើតអនុគណៈកម្មការប្រឆាំងការជ.ក.ផ.ក.មួយដែលមានរដ្ឋលេខាធិការក្រសួងមហាផ្ទៃជាប្រធាន។

## ផ្នែកអនុវត្តន៍កម្មវិធី

នៅក្នុងកម្មវិធីបង្ការទប់ស្កាត់ រាជរដ្ឋាភិបាលក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលនានាបានធ្វើការងារជាច្រើនដើម្បីផ្សព្វផ្សាយអំពីសិទ្ធិកុមារ ជាពិសេសអំពីបញ្ហានៃការជ.ក.ផ.ក.តាមរយៈវិទ្យុ ទូរទស្សន៍ សិក្ខាសាលា ការសំដែងរឿង ការដើរក្បួនយាត្រា ការផលិតនិងផ្សព្វផ្សាយឯកសារពត៌មាន ផ្ទាំងរូបភាព ទស្សនាវដ្តីព្រឹត្តិប័ត្រប្រតិទិន ជាពិសេសបានបញ្ចូលកម្មវិធីអប់រំទាក់ទងនឹងការជ.ក.ផ.ក.ទៅក្នុងកម្មវិធីអប់រំទាំងក្នុងនិងក្រៅប្រព័ន្ធ។ ទន្ទឹមនឹងនោះដែរ អង្គការមិនមែនរដ្ឋាភិបាលនិងក្រសួងពាក់ព័ន្ធមួយចំនួនបានសហការគ្នាធ្វើយុទ្ធនាការ

ប្រឆាំងនឹងការជ.ក.ផ.ក.នៅតាមបណ្ដាខេត្ត ក្រុងដែលកំពុងប្រឈមមុខនឹងបញ្ហាទាំងនេះ។ អង្គការអន្តរជាតិមួយចំនួនបានសហការជាមួយរាជរដ្ឋាភិបាលក្នុងការបើកវគ្គបណ្ដុះបណ្ដាលមន្ត្រីរាជការ ក្រសួងមន្ទីរពាក់ព័ន្ធ ការបង្កើតក្រុមឃ្លាំមើលតាមសហគមន៍ កម្មវិធីសន្តិសុខស្បៀង និងជំរុញចលនាសហគមន៍អោយចូលរួមតាមដាននិងការពារកុមារ។

នៅក្នុងកម្មវិធីការការពារ រាជរដ្ឋាភិបាលបានបង្កើតក្រុមស៊ើបអង្កេត ក្រុមការងារនីតិវិធីប្រតិបត្តិដើម្បីបង្ក្រាបបទល្មើសនិងបញ្ជូនជនល្មើសទៅតុលាការ ក្រុមប្រចាំការនិងបណ្ដាញទូរស័ព្ទពិសេស២៤ម៉ោងលើ២៤ម៉ោងសំរាប់ការហៅរកជំនួយ។ ក្នុងនោះអង្គការមិនមែនរដ្ឋាភិបាលក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងការចុះស៊ើបអង្កេតនិងជួយរំដោះកុមាររងគ្រោះ ផ្ដល់ការគាំទ្រផ្នែកច្បាប់ដើម្បីផ្ដន្ទាទោសដល់ជនល្មើសចងក្រងឯកសារច្បាប់ជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងអនុសញ្ញាស្ដីពីសិទ្ធិកុមារ ព្រមទាំងធ្វើសៀវភៅណែនាំផ្នែកច្បាប់សំរាប់មន្ត្រីអនុវត្តច្បាប់។ វគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាព និងផ្សព្វផ្សាយច្បាប់ដល់មន្ត្រីអនុវត្តច្បាប់ត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌ ក្រសួង អង្គការជាតិ និងអន្តរជាតិនានា។ ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាគឺជាផ្នែកមួយនៃបណ្ដាញអ៊ីនធើប៉ូល និងបានធ្វើបត្យាប័នជាមួយប្រទេសថៃ និងចិន ព្រមទាំងធ្វើកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តន៍កម្មវិធីជាតិប្រឆាំងការជួញដូរស្ត្រី និងកុមារ ជាមួយប្រទេសក្នុងអនុតំបន់មេគង្គទៀតផង។

នៅក្នុងកម្មវិធីស្ដារនិងអភិវឌ្ឍន៍សមត្ថភាព ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានបង្កើតនិងគ្រប់គ្រងរចនាសម្ព័ន្ធលើសេវាគាំទ្រ និងសង្គ្រោះបន្ទាន់។ ក្នុងនោះអង្គការមិនមែនរដ្ឋាភិបាលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការផ្ដល់សេវាទ្រទ្រង់កុមាររងគ្រោះ ដោយបង្កើតជាមណ្ឌលសំចត ផ្ដល់ការអប់រំអក្ខរកម្ម និងវិជ្ជាជីវៈ ផ្ដល់សេវាសុខភាព និងពិគ្រោះយោបល់ផ្លូវចិត្ត ព្រមទាំងជួយរកការងារអោយធ្វើ និងផ្ដល់ទុនសំរាប់ប្រកបរបរចិញ្ចឹមជីវិត។

អង្គការមិនមែនរដ្ឋាភិបាលបានយកចិត្តទុកដាក់ ក្នុងការធ្វើសមាហរណកម្មកុមារដែលជាមុខសញ្ញទៅសហគមន៍វិញ ក្នុងនោះសកម្មភាពសំខាន់ៗដែលបានអនុវត្តកន្លងមកមានដូចជា ទំនាក់ទំនងជាមួយបណ្ដាញរបស់មន្ទីរសង្គមកិច្ចតាមបណ្ដាខេត្ត និងអាជ្ញាធរដែនដីក្នុងការបំពេញបែបបទធ្វើសមាហរណកម្មផ្ទះផ្សារក្រុមគ្រួសារ និងញាតិមិត្តជិតខាង បង្កលក្ខណៈងាយស្រួលក្នុងជីវភាពរស់នៅដោយផ្ដល់ជាសំភារៈ



ទុន ជួយរកទីផ្សារ ផ្តល់ជំនាញដល់ក្រុមគ្រួសាររបស់កុមារ ផ្តល់ការប្រឹក្សាដល់គ្រួសារ និងកុមារ។ ក្នុងករណីមិនអាចបញ្ជូនទៅក្រុមគ្រួសារវិញ មានអង្គការមិនមែនរដ្ឋាភិបាលខ្លះបានផ្តល់ផ្ទះអោយរស់នៅជាក្រុមក្នុងរយៈពេលមានកំណត់ និងរកការងារអោយធ្វើ ឬរកជំរកចំលាស់ដោយមានការផ្សារភ្ជាប់នឹងការតាមដានបន្ត។ ក្នុងករណីឆ្លងប្រទេស រាជរដ្ឋាភិបាលបានរួមសហការជាមួយអង្គការ IOM និង UNICEF ធ្វើសមាហរណកម្មស្ត្រីនិងកុមាររងគ្រោះដោយសារការជួញដូរនេះទៅប្រទេសដើមវិញ។ អង្គការមិនមែនរដ្ឋាភិបាលក៏បានរួមចំណែកយ៉ាងសកម្មជាមួយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាក្នុងការជួយតាមដានបន្តលើកម្មវិធីសមាហរណកម្មនេះ។

## បទពិសោធន៍ល្អនៃកម្មវិធីការការពាររបស់ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃបានចុះហត្ថលេខានៅថ្ងៃទី០៤ខែមេសាឆ្នាំ២០០០លើអនុស្សរណៈនៃការយោគយល់គ្នាមួយជាមួយអង្គការ IOM, SCN, COHCHR, UNICEF & WVC ដើម្បីអនុវត្តគំរោងកម្មវិធី“ការអនុវត្តន៍ច្បាប់ប្រឆាំងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ”។ ក្នុងការរៀបចំគំរោង WVC បានធ្វើការសិក្សាវាយតំលៃមួយអំពីការអនុវត្តន៍ច្បាប់ កត្តារាំងស្ទះនិងឱកាស។ ការងារនេះមានការផ្តល់យោបល់ពីអង្គការជាតិនិងអន្តរជាតិ នាយនគរបាល និងមន្ត្រីនគរបាល និងមានការសហការយ៉ាងពេញលេញពីក្រសួងមហាផ្ទៃ។ គោលបំណងរបស់គំរោងការគឺការពារកុមារកម្ពុជាពីការកេងប្រវ័ញ្ចផ្លូវភេទ និងការចាប់រំលោភសេពសន្ថវៈដោយការពង្រឹងសមត្ថភាពប៉ូលីសក្នុងការស៊ើបអង្កេតករណីផ្សេងៗ ការជួយសង្គ្រោះជនរងគ្រោះ ការប្រើប្រាស់ប្រព័ន្ធដែលពាក់ព័ន្ធនានា ការចាប់ខ្លួនជនល្មើស និងបញ្ជូនខ្លួនទៅតុលាការ។ គណៈកម្មាធិការសំរបសំរួលគំរោងការនេះត្រូវបានដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការក្រសួងមហាផ្ទៃដោយធ្វើការយ៉ាងជិតស្និទជាមួយគណៈកម្មការដឹកនាំគំរោងការដែលមានតំណាងអង្គការទាំង៥ជាសមាជិក។

ភារកិច្ចនៃគំរោងការគឺ៖ ទី១ផលិតសំភារៈឯកសារបង្រៀននានាដោយមានជំនួយពីជំនាញការប៉ូលីសអន្តរជាតិនិងបុគ្គលិកក្រសួងមហាផ្ទៃ ទី២បង្រៀនប៉ូលីសថ្នាក់ស្នងការ ស្នងការរងខេត្តក្រុង ថ្នាក់ស្នងការរងទទួលបន្ទុកនគរបាលយុត្តិធម៌និងបើកសិក្ខាសាលាក្នុង១៣ខេត្តក្រុង និងទី៣ហ្វឹកហ្វឺនស៊ីជំរៅនូវបច្ចេកទេសអង្កេតដល់នគរបាល ចៅក្រម និងព្រះរាជអាជ្ញាក្រុងភ្នំពេញ និងបង្កើតការិយាល័យជំនាញពីរ គឺការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការិយាល័យការពារអនីតិជន។

លើសពីនេះ គឺមានការបង្កើតទូរស័ព្ទប្រចាំការពិសេស២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍។ ចាប់តាំងពីថ្ងៃ១៥-១០-២០០០រហូតមកដល់ថ្ងៃ១៥-១០-២០០១នេះ មាន១៨៦ករណីត្រូវបានរាយការណ៍មកគំរោងការ ហើយភាគច្រើនគឺបានទទួលពត៌មានតាមទូរស័ព្ទពិសេស។ ជនរងគ្រោះ៣១១នាក់ត្រូវបានជួយសង្គ្រោះ ក្នុងនោះ១៥០នាក់មានអាយុក្រោម១៨ឆ្នាំ ហើយជនល្មើស៧៥នាក់ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅតុលាការ។ ក្នុងចំណោមជនល្មើសទាំងនេះ ១៩នាក់បានរំលោភកុមារអាយុក្រោម១៥ឆ្នាំ។ កត្តាដែលនាំអោយគំរោងការនេះទទួលបានជោគជ័យគឺអាស្រ័យមានគោលការណ៍ដឹកនាំរបស់រាជរដ្ឋាភិបាលនិងផែនការជាតិ៥ឆ្នាំគោលការណ៍ដឹកនាំនិងការយកចិត្តទុកដាក់របស់អគ្គនាយកដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ អនុស្សរណៈថ្ងៃទី០៤មេសា២០០០ដែលជាមូលដ្ឋាននិងទុនយ៉ាងសំខាន់ក្នុងកិច្ចដំណើរការការងារ ការរួមចំណែកក្នុងការផ្តល់ពត៌មាននិងការបណ្តុះបណ្តាលរបស់សហគមន៍អន្តរជាតិ កិច្ចសហការយ៉ាងស្អិតរម្មួតជាមួយតុលាការ ស្ថាប័នអង្គការពាក់ព័ន្ធនិងប្រទេសជិតខាង ការខិតខំប្រឹងប្រែងរបស់នាយ នាយរង និងពលនគរបាលជំនាញក្រសួងនិងខេត្តក្រុង និងកំរិតថ្នៃប្រឌិតខ្ពស់ក្នុងការប្រើប្រាស់អស់លទ្ធភាពមធ្យោបាយសំភារៈដែលមាន។

**បទពិសោធន៍ល្អនៃកម្មវិធីបង្ការទប់ស្កាត់ អនុវត្តដោយសមាគមកុមារនិងក្តីស្រឡាញ់ (ស.ក.ស.)**

ស.ក.ស ចាប់ផ្តើមដំណើរការគំរោងការ“សិទ្ធិកុមារនិងការពារកុមារ” នៅឆ្នាំ១៩៩៩ នៅ១៤ភូមិក្នុងស្រុកមេសាង ខេត្តព្រៃវែង ជាប្រភពដែលកុមារត្រូវគេជួញដូរ។ គោលបំណងរបស់គំរោងគឺដើម្បីការពារនិងទប់ស្កាត់កុមារពីការជួញដូរ ការកេងប្រវ័ញ្ចផ្លូវភេទ និងទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ គំរោងការទទួលការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីអង្គការអង់គ្លេសសង្គ្រោះកុមារកម្ពុជា និងសហការជាមួយនាយកដ្ឋានសុខុមាលភាពកុមារ និងនាយកដ្ឋានអធិការកិច្ចនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មន្ទីរអភិវឌ្ឍន៍និងកសិកម្មខេត្ត និងអង្គការសិទ្ធិមនុស្សវីជីលែនកម្ពុជា។ គំរោងការនេះដំណើរការតាមរយៈបណ្តាញការងារមួយដែលមានក្រុមមិត្តជួយមិត្ត គណៈកម្មការអភិវឌ្ឍន៍ភូមិ ក្រុមម៉ែជួយម៉ែ ក្រុមឪជួយឪ និងអាជ្ញាធរមូលដ្ឋាន។

ស.ក.ស.បានហ្វឹកហ្វឺនបណ្តាញការងារខាងលើអំពីសិទ្ធិកុមារ និងបញ្ហាទាក់ទងនឹងការជ.ក.ផ.ក. ដើម្បីពង្រឹងយន្តការនេះក្នុងការការពារកុមារក្នុងសហគមន៍របស់គេ។ បណ្តាញការងារនេះមានភារកិច្ចដូចតទៅៈ ផលិតសំភារៈនិងឯកសារបង្រៀនដែលពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទលើកុមារ បង្រៀនពីវិធីប្រមូលពត៌មានដល់ក្លឹបកុមារនិងជនបង្គោលអំពីសិទ្ធិកុមារ បញ្ហាពាក់ពន្ធ័ការជួញដូរ ដើម្បីអោយគេបង្រៀនបន្តដល់សហគមន៍និងស្ថាប័នពាក់ព័ន្ធ និងផ្សព្វផ្សាយពត៌មានដល់សហគមន៍ មាតាបិតា និងសាធារណជន។

គំរោងការមាន៣ផ្នែកធំៗគឺៈ ហ្វឹកហ្វឺនពីសិទ្ធិកុមារ ឥណទានខ្នាតតូចនិងសន្តិសុខស្បៀង និងលើកទឹកចិត្តកុមារចូលសាលារៀន។ លទ្ធផល២ឆ្នាំនៃការអនុវត្តន៍គំរោងការមានដូចខាងក្រោមនេះៈ

- ចំនួនកុមារចេញមកធ្វើការនៅទីក្រុងថយចុះប្រមាណ៧០%។
- កុមារ១១២៥នាក់ក្នុងចំណោមកុមារ១៥០០នាក់ដែលបានឈប់រៀននិងមិនបានចុះឈ្មោះចូលរៀនត្រូវបានបញ្ជូនទៅសាលារៀនវិញ។
- មនុស្សពេញវ័យជាង៧០០០នាក់និងកុមារប្រមាណ៥០០០នាក់បានឆ្លងកាត់វគ្គផ្សព្វផ្សាយពីសិទ្ធិកុមារនិងបញ្ហាពាក់ពន្ធ័ការជួញដូរកុមារ។
- ពីថ្ងៃទី០១ខែមិថុនា២០០០ដល់ថ្ងៃទី៣១ខែសីហា២០០១ គំរោងបានទប់ស្កាត់ដោយជោគជ័យនូវករណីឆបោកក្នុងបំណងជួញដូរនិងបំរើផ្លូវភេទចំនួន២៣លើកដែលកើតឡើងចំពោះកុមារីចំនួន៦៧នាក់អាយុពី១២ដល់១៦ឆ្នាំ តាមរយៈក្លឹបកុមារនិងជនបង្គោល។

គំរោងនេះអនុវត្តបានដោយជោគជ័យអាស្រ័យដោយមានការប្តេជ្ញាចិត្តខ្ពស់ និងការសហការល្អនៃក្រុមមិត្តជួយមិត្ត ក្លឹបកុមារ ជនបង្គោល និងសមាជិកនៃបណ្តាញការងារដទៃទៀតក្នុងតំបន់គោលដៅ កិច្ចសហការល្អពីអាជ្ញាធរមូលដ្ឋាន ការចូលរួមផ្តល់ពត៌មានថ្មីៗនិងទាន់ពេលវេលាពីសហគមន៍ ការផ្សារភ្ជាប់កម្មវិធីទប់ស្កាត់ជាមួយផ្នែកដទៃទៀតនៃគំរោង ជាពិសេសកម្មវិធីសន្តិសុខស្បៀងដើម្បីបង្កើនផលិតផលកសិកម្មនិងប្រាក់ចំណូលក្នុងគ្រួសារ។

“ខ្ញុំបានរត់ចូលដីថៃដើម្បីរកស៊ីលីបាវអង្ករជាមួយមិត្តភក្តិខ្ញុំ។ គេបានចាក់ថ្នាំញៀនអោយខ្ញុំមានកំលាំងធ្វើការ។ ក្រោយមកខ្ញុំទ្រាំមិនបានក៏រត់មកស្រុកខ្មែរវិញ ហើយរកស៊ីដើរខាត់ស្បែកជើងនៅភ្នំពេញ។ ថ្ងៃមួយមានជនបរទេសម្នាក់បានហៅខ្ញុំទៅផ្ទះរបស់គេ។ គេអោយខ្ញុំរួមភេទជាមួយគេ ហើយគេអោយលុយខ្ញុំក្នុងម្តងចំនួន ៣០ដុល្លា។ ខ្ញុំចង់ប្រាប់ថា...ខ្ញុំស្អប់ជនបរទេស!”។

នេះគឺជាសំដីរបស់កុមារា ត.វ.ន. អាយុ១៤ឆ្នាំ

“ខ្ញុំមានស្រុកកំណើតនៅប៉ោយប៉ែត។ ខ្ញុំរស់នៅជាមួយយាយខ្ញុំ ព្រោះឪពុកម្តាយខ្ញុំបានលែងគ្នា។ ថ្ងៃមួយមានអ្នកជិតខាងម្នាក់បានមកលួងលោមខ្ញុំថានឹងនាំខ្ញុំទៅធ្វើការនៅហាងគុយទាវមួយក្រែងបានកំរៃខ្លះមកចិញ្ចឹមជីវិត។ ខ្ញុំក៏ព្រមទៅជាមួយគេ ប៉ុន្តែគេបែរជាយកខ្ញុំទៅលក់អោយផ្ទះបនមួយនៅប្រទេសថៃទៅវិញ។ នៅទីនោះ គេបង្ខំខ្ញុំអោយទទួលភ្ញៀវជាបន្តបន្ទាប់។ គេគំរាមខ្ញុំថា បើខ្ញុំមិនព្រមទេ គេនឹងយកខ្ញុំទៅលក់នៅក្រុងថេប ដល់ពេលនោះសូម្បីតែពន្លឺថ្ងៃក៏ខ្ញុំមិនបានឃើញផង។ បន្ទាប់មកខ្ញុំក៏លួចរត់ចេញមក ហើយសព្វថ្ងៃមជ្ឈមណ្ឌលកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិកំពុងជួយប្តឹងចាប់មេខ្យល់នោះ”។

នេះគឺជាសំដីរបស់កុមារី ក.ស.ណ. អាយុ១៧ឆ្នាំ

## តើនរណាជាអ្នកដែលមានកំហុសធ្ងន់ធ្ងរជាងគេ? អតិថិជនដែលរួមភេទជាមួយកុមារ? មាតាបិតាដែលលក់កូនរបស់ខ្លួន? ឬក៏យើងទាំងអស់គ្នានៅក្នុងសង្គមជាតិទាំងមូលពុំទាន់យកចិត្តទុកដាក់ពេញទំហឹងក្នុងការបញ្ឈប់បញ្ហានេះ?

# ៤

# ការលំបាកនិងឧបសគ្គចំពោះមុខ

“ពេលនេះខ្ញុំមានផ្ទុកមេរោគអេដស៍...ព្រោះខ្ញុំត្រូវគេបោកយកទៅលក់អោយផ្ទះបន។ ក្រោយមកម្តាយខ្ញុំក៏លក់ខ្ញុំបន្តទៀត។ បងប្អូនខ្ញុំស្រី៧២នាក់ទៀតក៏គាត់នាំយកទៅលក់ដែរ ដោយសារគាត់លេងល្បែង។ គាត់បាននាំខ្ញុំទៅលក់ពីកន្លែងមួយទៅកន្លែងមួយទៀត ដោយបើកយកលុយពីផ្ទះបន ហើយទុកអោយខ្ញុំនៅជាមួយគេដើម្បីដោះបំណុល។ ខ្ញុំគ្មានអ្វីត្រូវនិយាយទេ... គ្រាន់តែចង់អោយក្មេងស្រីៗទាំងអស់ចេះប្រយ័ត្នខ្លួនកុំអោយដូចខ្ញុំ...ព្រោះមានមនុស្សដែលយើងស្គាល់ច្រើនណាស់តែយើងមិនទុកចិត្តថាអ្នកណាល្អ អ្នកណាខិលខូចទេ”។

នេះគឺជាសំដីរបស់ក្មេងស្រីឈ្មោះ ឈ.ស.ជ. អាយុ១៨ឆ្នាំ

## ហេតុអ្វីបានជាកុមារក្លាយទៅជាកូនបំណុលនិងរងគ្រោះដោយសារទង្វើរបស់មនុស្សចាស់?

## តើសោកនាដកម្មនេះនៅបន្តអូសបន្លាយយូរប៉ុនណាទៀត?



# ការលំបាកនិងឧបសគ្គចំពោះមុខ

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងពីសំណាក់រាជរដ្ឋាភិបាលនិងសង្គមស៊ីវិលរយៈពេលកន្លងមកក៏ដោយក៏ជាក់ស្តែងយើងសង្កេតឃើញនៅមានកុមារធ្លាក់ខ្លួនក្នុងអំពើពេស្យាចារជារៀងរាល់ថ្ងៃនៅឡើយហើយបទពិសោធន៍ក្នុងការអនុវត្តន៍កម្មវិធីទាំង៤នៃផែនការជាតិ៥ឆ្នាំប្រឆាំងការជ.ក.ផ.ក.កន្លងមកបានបង្ហាញអោយឃើញនូវការលំបាកនិង ឧបសគ្គចំពោះមុខជាច្រើនដូចជា :

## ក. ការបង្ការទប់ស្កាត់

- ការផ្សព្វផ្សាយច្បាប់ពុំទាន់បានទូលំទូលាយនិងអត្ថបទច្បាប់មានលក្ខណៈពិបាកយល់សំរាប់ប្រជាពលរដ្ឋ ។
- ប្រពន្ធ័ផ្សព្វផ្សាយដូចជាសារពត៏មាន វិទ្យុ ទូរទស្សន៍ពុំទាន់បានយកចិត្តទុកដាក់ពីការជ.ក.ផ.ក. និងមិនគ្របដណ្តប់ទូទាំងប្រទេសជាពិសេសនៅតាមជនបទដាច់ស្រយាលហើយការផ្សព្វផ្សាយមានតំលៃខ្ពស់ ។
- មានការលំបាកក្នុងការប្រមូលផ្តុំប្រជាជនមករៀនសូត្រដោយគាត់មានជីវភាពក្រីក្រនិងចំណេះដឹងទាប ។
- ប្រជាជនពុំទាន់បានចូលរួមផ្តល់ពត៏មានអោយបានសកម្មជូនអាជ្ញាធរដោយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន ។
- ជនមួយចំនួនចូលចិត្តរួមភេទជាមួយក្មេងៗ នាំអោយការជួញដូរកុមារកើនឡើង ។

## ខ. ការការពារ

- ច្បាប់នៅមានការខ្វះចន្លោះ ពុំគ្របដណ្តប់លើគ្រប់ករណី និងគ្មានច្បាប់ដោយឡែកសំរាប់កុមារ ។
- ការអនុវត្តន៍ច្បាប់ពុំទាន់មានប្រសិទ្ធភាព ដោយមន្ត្រីអនុវត្តច្បាប់មួយចំនួននិងប្រជាជនពុំចេះច្បាប់ មានអំពើពុករលួយដូចជាមានការធ្វើអន្តរាគមន៍ពីអ្នកមានអំណាចពេលចុះសង្គ្រោះកុមារ រឿងក្តីខ្លះមិនអនុវត្តតាមនីតិវិធីច្រើនតែធ្វើការសំរុះសំរួលដោយមិនផ្តន្ទាទោសជនល្មើស មន្ត្រីមូលដ្ឋានខ្លះលាក់ពត៏មាន បំភ័យជនរងគ្រោះមិនអោយប្តឹងហើយនីតិវិធីដោះស្រាយក្តីមានភាពយឺតយ៉ាវ ។
- ពុំទាន់មានចៅក្រមជំនាញខាងកុមារ មន្ត្រីអនុវត្តច្បាប់ខ្វះជំនាញខាងសិទ្ធិកុមារ ហើយតុលាការមិនសូវ

យកចិត្តទុកដាក់ពិចារណាចំពោះសេចក្តីសន្និដ្ឋានរបស់មេធាវី និងចំលើយរបស់កុមាររងគ្រោះ។

- ការសហការរវាងប៉ូលីស ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជីនិងអាជ្ញាធរមូលដ្ឋានពុំមានលក្ខណៈល្អប្រសើរ។
- ពុំមានភស្តុតាងគ្រប់គ្រាន់សំរាប់ចោទប្រកាន់ជនល្មើស ដោយសារប្រជាជនពុំទាន់យល់ដឹងពីសារសំខាន់នៃការរក្សាទុកវត្ថុតាងទាំងនោះ។
- មានការហូរចូល ការប្រើប្រាស់ ការផលិតនិងការជួញដូរគ្រឿងញៀន។

## គ. ការស្តារនិងអភិវឌ្ឍន៍សមត្ថភាព

- ខ្វះមណ្ឌលទទួលនិងស្តារនីតិសម្បទា មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនិងមណ្ឌលសំរាប់កុមាររងគ្រោះដែលផ្ទុកមេរោគអេដស៍។
- សមត្ថភាពមន្ត្រីធ្វើការងារលើផ្នែកនេះនៅមានកំរិតខាងការពិគ្រោះយោបល់ និងចិត្តសាស្ត្រកុមារ។

## ឃ. សមាហរណកម្ម

- កុមាររងគ្រោះពុំមានអត្តសញ្ញាណ និងពុំស្គាល់ទីលំនៅពិតប្រាកដ។
- មានការរើសអើង ជាហេតុនាំអោយកុមារមិនអាចសំរបខ្លួនក្នុងសហគមន៍បាន។
- កុមារដែលបានឆ្លងកាត់ការបណ្តុះបណ្តាលវិជ្ជាជីវៈហើយ ពុំអាចរកកំរៃចិញ្ចឹមជីវិតបានដោយសារជំនាញមួយចំនួនពុំឆ្លើយតបទៅនឹងតំរូវការទីផ្សារនិងសហគមន៍ហើយទុនសំរាប់ជួយកុមាររងគ្រោះនៅមានកំរិត។
- ពិបាកក្នុងការបណ្តុះបណ្តាលនិងរកការងារអោយធ្វើ ដោយកុមាររងគ្រោះមិនចេះអក្សរ សុខភាពផ្លូវកាយនិងចិត្តទន់ខ្សោយ។
- សមត្ថភាពរបស់រដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងការចុះតាមដានអោយបានជិតដល់ចំពោះកុមារដែលបានធ្វើសមាហរណកម្មត្រឡប់ទៅសហគមន៍របស់ពួកគេវិញនៅមានកំរិត។

## ង. កិច្ចសំរបសំរួលនិងសហប្រតិបត្តិការ

- ប្រព័ន្ធប្រមូលពត៌មាន និងយន្តការតាមដានការអនុវត្តន៍ផែនការជាតិពុំទាន់មាននៅគ្រប់ជាន់ថ្នាក់បណ្តាលអោយខ្វះស្ថិតិច្បាស់លាស់ពីបញ្ហាការជ.ក.ផ.ក. ការផ្លាស់ប្តូរពត៌មាននិងបទពិសោធន៍ព្រមទាំងការចែកចាយសំភារៈផ្សព្វផ្សាយដែលផលិតរួចពុំទាន់បានទូលំទូលាយ។



- ការចូលរួមរបស់កុមារ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការតាមដានការអនុវត្តន៍ផែនការជាតិនៅមានកំរិត រីឯសមត្ថភាពមន្ត្រីសំរបសំរួល និងថវិកាសំរាប់ការងារនេះនៅមានកំរិតទាប ។
- កិច្ចសហការជាមួយអ្នកសារពត៌មានដើម្បីផ្សព្វផ្សាយនិងជំរុញការអនុវត្តន៍ច្បាប់ គោលនយោបាយ និងកម្មវិធីពាក់ពន្ធ័នានានៅមានកំរិតទាប ។
- ពុំទាន់មានកិច្ចសហការល្អជាមួយផ្នែកឯកជនក្នុងសកម្មភាពទប់ស្កាត់ ការបណ្តុះបណ្តាល ការផ្តល់ការងារ និងការទ្រទ្រង់សេវាស្តារនីតិសម្បទា ។

## ការប្ដេជ្ញាចិត្តតំបន់អាស៊ីអគ្នេយ៍និងប៉ាស៊ីហ្វិកប្រឆាំងការជ.ក.ផ.ក.ខែតុលា២០០១ នៅទីក្រុងបាងកក

- ធានាការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ សេចក្តីប្រកាសទីក្រុងស្តុកខុលម៍ និងផែនការសកម្មភាពអោយមានប្រសិទ្ធភាព និងផ្តត់ផ្គង់ធនធានគ្រប់គ្រាន់សំរាប់សំរេចបំណងនេះ ។
- គាំទ្រដំណើរការឈានឆ្ពោះទៅសន្និសីទពិភពលោកលើកទី២ ។
- ជំរុញអោយមានការផ្តល់សច្ចាប័នអោយបានឆាប់លើឯកសារគតិយុត្តិអន្តរជាតិដែលការពារកុមារ រួមមានអនុសញ្ញា ILOលេខ១៨២ ស្តីពីការហាមឃាត់និងចាត់វិធានការជាបន្ទាន់ដើម្បីលុបបំបាត់ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ពិធីសារបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ស្តីពីការជួញដូរកុមារ ពេស្យាចារកុមារ និងអំពើកាមសាស្ត្រលើកុមារនិងពិធីសារបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងប្រទេសស្តីពីការទប់ស្កាត់និងការដាក់ទណ្ឌកម្មទៅលើការជួញដូរមនុស្ស ជាពិសេសទៅលើស្ត្រី និងកុមារ ។
- ចាត់វិធានការចំរុះនិងទូលំទូលាយប្រឆាំងការជ.ក.ផ.ក. ។
- កែលំអច្បាប់និងនីតិវិធីពាក់ពន្ធ័ទាំងឡាយ គោលនយោបាយ កម្មវិធីនិងយន្តការ និងបណ្តុះបណ្តាលបុគ្គលិកធ្វើការពាក់ព័ន្ធនឹងការប្រឆាំងការជ.ក.ផ.ក. ដោយធ្វើអោយគេយល់ថាកុមារដែលរងគ្រោះដោយអំពើកេងប្រវ័ញ្ចផ្លូវភេទជាជនរងគ្រោះមិនមែនជាឧក្រិដ្ឋជនទេ ។
- ដោះស្រាយភាពពាក់ព័ន្ធគ្នារវាងការកេងប្រវ័ញ្ចផ្លូវភេទនិងការជួញដូរកុមារ និងកែលំអច្បាប់ដើម្បីលុបបំបាត់បាតុភូតទាំងនេះដោយធានាថាកុមាររងគ្រោះដោយអំពើជួញដូរមិនត្រូវបានចាត់ទុកថាជាជនអន្តោប្រវេសន៏ខុសច្បាប់ឡើយ ហើយត្រូវធានាថាពួកគេអាចទទួលបាននូវប្រពន្ធ័គាំទ្រនានាដើម្បីការពារសន្តិសុខ និងការធ្វើមាតុភូមិនិវត្តន៏ដោយសុវត្ថិភាព ។
- ពង្រីកកិច្ចសហប្រតិបត្តិការនិងការសំរបសំរួលប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្នុងចំណោមរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសមាជិកដទៃៗទៀតនៃសង្គមស៊ីវិល ផ្នែកឯកជន ប្រពន្ធ័ឃោសនា អង្គការអន្តររដ្ឋាភិបាល រួមមានអង្គការថ្នាក់តំបន់ និងយុវជន ។
- ធ្វើអោយប្រសើរឡើងនូវការស្រាវជ្រាវ ការប្រមូលពត៏មាននិងទិន្នន័យ ដើម្បីផ្តល់ពត៏មានដល់ផ្នែកគោលនយោបាយ និងកម្មវិធីក្នុងការដោះស្រាយការកេងប្រវ័ញ្ចផ្លូវរភេទលើកុមារ ។
- កែលំអដំណើរការពិនិត្យតាមដាននៅគ្រប់កំរិតដែលទាក់ទងនឹងការកេងប្រវ័ញ្ចនិងធានាពីចេរភាពរបស់វា ។
- ពង្រឹងការចូលរួមរបស់យុវជនប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងគាំទ្រសកម្មភាពនិងបណ្តាញការពារកុមាររបស់ពួកគេ ។

# ៥

# ក្តីស្រម៉ៃនិងសំណូមពររបស់កុមារនិងយុវជន

# អនាគតរបស់យើងខ្ញុំ គឺស្ថិតនៅក្នុងដៃរបស់លោកអ្នក!








# សូមមេត្តាជួយធ្វើអោយក្តីស្រមៃរបស់យើងខ្ញុំក្លាយទៅជាការពិត!







# សំណូមពររបស់កុមារនិងយុវជន

## ចំពោះរាជរដ្ឋាភិបាល

- សូមអោយរាជរដ្ឋាភិបាលបង្កើនការទប់ស្កាត់ តាមរយៈការអប់រំក្នុងនិងក្រៅប្រព័ន្ធ ចុះណែនាំដើម្បីបំផុសគំនិតប្រជាជនអោយចេះសហការគ្នាដោះស្រាយបញ្ហា ។
- សូមអោយរាជរដ្ឋាភិបាល ជាពិសេសក្រសួងពត៌មាន និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈទប់ស្កាត់ និងលុបបំបាត់ការហូរចូលនូវវប្បធម៌ពាលាអាវ៉ាសែ ដោយធ្វើការត្រួតពិនិត្យការនាំចូល និងការផ្សព្វផ្សាយវប្បធម៌បរទេសដូចជា រឿងភាគ វីដេអូ ទស្សនាវដ្ដីសិចស៊ី ដែលជាឧបករណ៍ជំរុញអោយប្រជាជនកើតមានចំណង់ខាងផ្លូវភេទ ដែលនាំអោយមានការរំលោភផ្លូវភេទលើកុមារ ។
- សូមបង្កើតអោយមានសាលារៀនគ្រប់គ្រាន់ អោយកុមារក្រីក្របានចូលរៀនគ្រប់ៗគ្នាដោយឥតបង់ថ្លៃ ដើម្បីបង្កើនចំណេះដឹងកុំអោយចាញ់បោកគេ ហើយសូមជួយដល់គ្រួសារក្រីក្រដោយបង្កើនចំណូលគ្រួសារ ដើម្បីកុំអោយយកកូនឬសាច់ញាតិទៅលក់ ។
- សូមបង្ក្រាបបនស្រី រំដោះកុមាររងគ្រោះ បង្កើនមជ្ឈមណ្ឌលថែទាំកុមាររងគ្រោះតាមតំបន់នានាដែលមិនទាន់មាន និងជួយបណ្ដុះបណ្ដាលវិជ្ជាជីវៈផ្សេងៗ ដើម្បីអោយពួកគេមានជីវភាពរស់នៅសមរម្យទៅអនាគត ។
- ជួយពង្រឹងប្រព័ន្ធអប់រំ និងប្រព័ន្ធផ្សព្វផ្សាយអោយបានទូលំទូលាយ ជាពិសេសផ្សព្វផ្សាយពីអនុសញ្ញាស្ដីពីសិទ្ធិកុមារនិងបញ្ហាជ.ក.ផ.ក.ទៅគ្រប់តំបន់អោយបានយល់ជ្រួតជ្រាប ។
- អនុម័តច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងបំបាត់បនល្បែងស៊ីសងទាំងតូចទាំងធំដែលបណ្ដាលអោយមានការជួញដូរកុមារដើម្បីយកប្រាក់មកលេងល្បែង ។
- ធានាសុវត្ថិភាពរបស់កុមារ ដោយចាត់វិធានការតឹងរ៉ឹងនិងអោយបានឆាប់ ដើម្បីលុបបំបាត់ការជួញដូរកុមារទៅបរទេស ។
- សូមរដ្ឋាភិបាលពង្រឹងការផ្សព្វផ្សាយ និងការអនុវត្តន៍ច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ចាត់វិធានការដែលមានស្រាប់អោយមានប្រសិទ្ធភាពដោយផ្ដន្ទាទោសយ៉ាងធ្ងន់ធ្ងរដល់ឧក្រិដ្ឋជនដែលជួញដូរកុមារ និងរួមភេទជាមួយកុមារ ។



- បង្កើតគណៈកម្មការតាមដានអំពើជ.ក.ផ.ក.នៅតាមបណ្តាខេត្ត ក្រុង និងព្រំដែន។
- កំចាត់អោយអស់នូវអំពើពុករលួយដោយចាត់វិធានការអោយបានតឹងរ៉ឹងចំពោះអាជ្ញាធរនៅតាមមូលដ្ឋាន ជាពិសេសផ្តន្ទាទោសជាទំងន់ទៅលើអាជ្ញាធរណាដែលឃុបឃិតជាមួយមេបន។
- ធានាអោយមានការចូលរួមពីកុមារ និងយុវជនក្នុងការធ្វើផែនការ ការអនុវត្តន៍ ការត្រួតពិនិត្យតាមដាន និងវាយតំលៃលើកម្មវិធីលុបបំបាត់ការជ.ក.ផ.ក.។
- ទាក់ទងនឹងបញ្ហាប្រទេសក្នុងតំបន់ រាជរដ្ឋាភិបាលត្រូវពង្រឹងកិច្ចសហការគ្នាផ្លាស់ប្តូរបទពិសោធន៍គ្នា និងចាត់វិធានការជាលាយលក្ខណ៍អក្សរ ឬបង្កើតច្បាប់ហើយអនុវត្តរួមគ្នាឱ្យបានត្រឹមត្រូវ។
- សូមអោយរាជរដ្ឋាភិបាលចាត់វិធានការទប់ស្កាត់អោយបានតឹងរ៉ឹងចំពោះការនាំចូល និងការប្រើប្រាស់គ្រឿងញៀនគ្រប់ប្រភេទក្នុងប្រទេសកម្ពុជា និងដាក់ទោសធ្ងន់ធ្ងរដល់ជនល្មើស។ លើកកំពស់ការយល់ដឹងដល់សាធារណៈជន ជាពិសេសកុមារអំពីផលប៉ះពាល់នៃគ្រឿងញៀន ព្រមទំាងចុះជួយជាបន្ទាន់ដល់កុមារដែលប្រើប្រាស់គ្រឿងញៀនដើម្បីធ្វើការយ៉ាងជិតស្និទជាមួយពួកគេ និងបង្កើតមជ្ឈមណ្ឌលកែប្រែ និងផ្តាច់គ្រឿងញៀន ដើម្បីផ្តល់ឱកាសអោយកុមារអាចកែខ្លួនបាន និងចូលរួមក្នុងសកម្មភាពសង្គមដោយគ្មានការរើសអើង។
- សូមអោយរាជរដ្ឋាភិបាលសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយ ដើម្បីលើកកំពស់ការយល់ដឹងដល់ក្រុមគ្រួសារ និងសហគមន៍អំពីជំងឺអេដស៍ ផលប៉ះពាល់ទំាងឡាយនៃជំងឺនេះ។
- សូមកុំអោយមានអំពើរើសអើងចំពោះកុមាររងគ្រោះដោយសារជ.ក.ផ.ក.កុមារផ្ទុកមេរោគអេដស៍ និងកុមារដែលធ្លាប់ញៀនគ្រឿងញៀន។

## ចំពោះអង្គការមិនមែនរដ្ឋាភិបាល

- ត្រូវតាមដាន ស៊ើបអង្កេតអោយបានល្អិតល្អន់អំពីបញ្ហាជ.ក.ផ.កហើយរួមសហការជិតស្និទជាមួយក្រសួងមានសមត្ថកិច្ចជួយសង្រ្គោះរំដោះកុមារដែលរងគ្រោះ ផ្តល់នូវការគាំពារ និងលើកទឹកចិត្តដល់កុមារ និងបង្កើនកម្មវិធីអប់រំក្រៅប្រព័ន្ធ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ពួកគេ។
- ធ្វើការផ្សព្វផ្សាយពីសិទ្ធិកុមារ បញ្ហាជ.ក.ផ.ក និងច្បាប់ដែលពាក់ព័ន្ធដល់ប្រជាជនដែលនៅទីជនបទដាច់ស្រយាលអោយបានយល់ដឹងនិងជួយពាំនាំ និងរំលឹកដល់រាជរដ្ឋាភិបាលអំពីសំណូមពររបស់កុមារ។

- ពង្រឹងសមត្ថភាពកុមារ និងយុវជន និងបុគ្គលិកពាក់ព័ន្ធដើម្បីធានានូវគុណភាពនៃការចូលរួមរបស់កុមារ និងយុវជនក្នុងការងារលុបបំបាត់ការជ.ក.ផ.ក ។

## ចំពោះក្រុមគ្រួសារនិងសហគមន៍

- ក្រុមគ្រួសារ មាតាបិតា ឬអាណាព្យាបាលត្រូវយល់ដឹងអំពីសិទ្ធិកុមារ ត្រូវបញ្ជូនកូនអោយទៅសាលារៀនដោយគ្មានការរើសអើងថាកូនស្រី ឬប្រុសឡើយ ។ គាត់ត្រូវផ្តល់ដំបូន្មានល្អៗដល់កុមារ ពន្យល់អោយកុមារយល់ដឹងពីបញ្ហាសង្គម និងដំណោះស្រាយ ផ្តល់នូវភាពកក់ក្តៅ និងលើកទឹកចិត្តអោយកុមារបានប្រើប្រាស់សិទ្ធិសមស្រប រួមមានទាំងសិទ្ធិបញ្ចេញយោបល់ផង ។ គាត់មិនត្រូវប្រើកុមារជាឧបករណ៍ដោះស្រាយបញ្ហាផ្ទាល់ខ្លួនឡើយ ហើយក៏មិនត្រូវប្រើអំពើហិង្សានៅក្នុងគ្រួសារដែរ ។
- សហគមន៍ត្រូវយកចិត្តទុកដាក់ចំពោះកុមារដោយមិនត្រូវរើសអើង ត្រូវណែនាំកុំអោយមានអំពើហិង្សាតាមគ្រួសារ បង្កអោយមានការទុកចិត្តគ្នារវាងប្រជាជននិងរដ្ឋអំណាចមូលដ្ឋាន និងចេះជួយគ្នា ហើយសូមអោយអាជ្ញាធរដែនដីធ្វើការកោះប្រជុំជាប្រចាំ ដើម្បីផ្តល់នូវចំណេះដឹងថ្មីៗដែលទាក់ទងនឹងបញ្ហាជ.ក.ផ.ក ។

## ចំពោះក្រុមកុមារនិងយុវជន

- ក្រុមកុមារត្រូវក្លាហាន ហ៊ាននិយាយបកស្រាយពីការពិតនៃបញ្ហាដែលទាក់ទងនឹងការជ.ក.ផ.ក ដែលខ្លួនបានជួបប្រទះ ឬបានឆ្លងកាត់ ព្រោះកុមារជាសាក្សីយ៉ាងសំខាន់ដើម្បីវែកមុខជនដៃដល់ និងត្រូវហ៊ានធ្វើការតស៊ូមតិទៅដល់មជ្ឈដ្ឋាននានា និងរាជរដ្ឋាភិបាល ។
- កុមារត្រូវរួមសហការជាមួយយុវជន ទាំងក្នុងនិងក្រៅប្រទេសដើម្បីជួយកុមាររងគ្រោះ និងកុមារងាយរងគ្រោះដោយការជ.ក.ផ.ក និងចេះការពារសិទ្ធិដែលខ្លួនមានដោយចេះប្រើប្រាស់អោយអស់នូវសក្តានុពលភាពរបស់ខ្លួនដើម្បីការពារផលប្រយោជន៍របស់កុមារ ។
- ក្រុមយុវជនត្រូវធ្វើជាគំរូល្អចំពោះកុមារ និងត្រូវចេះលើកទឹកចិត្តកុមាររងគ្រោះកុំអោយអស់សង្ឃឹម ។ យុវជនគឺជាអន្តរការី និងជាកត្តាលីករយ៉ាងមានប្រសិទ្ធភាពក្នុងការផ្តល់យោបល់បំផុស និងផ្សព្វផ្សាយឱ្យកុមារបានយល់ដឹងពីអនុសញ្ញាស្តីពីសិទ្ធិកុមារ បញ្ហាជ.ក.ផ.ក និងក្នុងការតស៊ូមតិជំនួសមុខអោយកុមារដែលរងគ្រោះ និងកុមារដែលងាយរងគ្រោះ ។



- យុវជននិងយុវជននៃបណ្តាប្រទេសដែលជាហត្ថលេខីនៃសេចក្តីប្រកាសនាទីក្រុងស្តុកខុលម៍ ត្រូវចេះចងបណ្តាញ និងរួមកំលាំងគ្នាដើម្បីស្វែងរកដំណោះស្រាយលើបញ្ហានេះ ព្រមទាំងដើរតួនាទីជាអ្នកសង្កេតការណ៍ក្នុងការអនុវត្តន៍ច្បាប់ប្រឆាំងនឹងការជ.ក.ផ.ករបស់រដ្ឋាភិបាលនីមួយៗ ។

# ទស្សនៈរបស់ខ្ញុំចំពោះការជួញដូរ



ឯ.ឧ **គឹម សុខា** ប្រធានគណៈកម្មការការពារសិទ្ធិមនុស្សនិងទទួលពាក្យបណ្តឹងនៃព្រឹទ្ធសភា

"...ទាក់ទងនឹងបញ្ហាការជ.ក.ផ.ក. យើងមានច្បាប់និងយន្តការមួយចំនួន ប៉ុន្តែការអនុវត្តន៍ជាក់ស្តែងនៅខ្សោយ ដោយការអនុវត្តន៏ច្បាប់នៅមិនទាន់មានប្រសិទ្ធភាព និងខ្វះយន្តការការពារកុមារនៅទូទាំងប្រទេសនៅឡើយ។ ភាពក្រីក្រគឺជាកត្តាមួយក្នុងចំណោមកត្តាផ្សេងៗទៀតដែលនាំអោយមានការកើនឡើងនូវការជ.ក.ផ.ក.នៅកម្ពុជា។ យើងត្រូវការច្បាប់បន្ថែមទៀតព្រមទាំងការផ្សព្វផ្សាយទូលំទូលាយ។ ព្រឹទ្ធសភានឹងជំរុញការអនុម័តច្បាប់ដែលព្រាងដោយរដ្ឋាភិបាលឱ្យបានលឿនដើម្បីបំពេញបន្ថែមទៅលើកង្វះខាតនៃច្បាប់ដែលមានស្រាប់ និងសំរួលតុលាការក្នុងការអនុវត្តន៏ការងាររបស់ខ្លួនដើម្បីកុំឱ្យជនខិលខូចរួចខ្លួនពីអំណាចច្បាប់។ ដើម្បីធ្វើច្បាប់ឱ្យបានល្អនៅមុនពេលអនុម័តរដ្ឋសភានិងព្រឹទ្ធសភាត្រូវធ្វើវេទិកាសាធារណៈ សួរមតិពីប្រជាជនជាពិសេសសង្គមស៊ីវិលដើម្បីបានដឹងថាច្បាប់នោះមានចន្លោះត្រង់ណា ហើយពិបាកអនុវត្តត្រង់ណា។ សង្គមស៊ីវិលឬមហាជនអាចផ្តល់គំនិតឬធ្វើសំនូមពរដល់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា និងក្រសួងពាក់ព័ន្ធនានា ដើម្បីធ្វើសេចក្តីព្រាងច្បាប់ប្រកបដោយគុណភាព និងដាក់ជូនទៅរដ្ឋសភានិងព្រឹទ្ធសភាអនុម័ត..."។

លោកជំទាវ **មួរ សុខហួរ** រដ្ឋមន្ត្រីក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន

"...បញ្ហារបស់កុមារគឺជាក្តីកង្វល់របស់យើងទាំងអស់គ្នាដែលទាមទារនូវដំណោះស្រាយដ៏មានប្រសិទ្ធភាពដោយត្រូវធ្វើឱ្យមានការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ទន្ទឹមគ្នាជាមួយនឹងការអភិវឌ្ឍន៍ផ្នែកសង្គម។ ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជនមានផែនការ៥ឆ្នាំគឺ **"នារីរតនៈ"** ដើម្បីលើកស្ទួយឱ្យស្រ្តី រួមមានទាំងយុវនារី និងកុមារីដែលជារតនៈសម្បត្តិជាតិអោយទទួលបានសិទ្ធិរបស់ខ្លួន។ បច្ចុប្បន្ននេះក្រសួងកិច្ចការនារីកំពុងតែបើកយុទ្ធនាការមួយប្រឆាំងការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារនិងស្រ្តីនៅក្នុងខេត្តក្រុងចំនួន៦ដែលកំពុងប្រឈមមុខនឹងបញ្ហានេះធ្ងន់ធ្ងរជាងគេ..."។





លោក **អ៊ូលើហ៏ បាន់ ហាវ៉ុល** ប្រធានអង្គការន័រវេស្ស៊ែសង្គ្រោះកុមារកម្ពុជា និងជាអ្នកសម្របសម្រួលសម្ព័ន្ធអង្គការសង្គ្រោះកុមារ

"...ការជ.ក.ផ.ក.គឺជាបញ្ហាដ៏ធំនិងស្មុគស្មាញ។ មានការខិតខំជាច្រើនពីរដ្ឋាភិបាលប៉ុន្តែបញ្ហានេះនៅតែកើនឡើង។ យើងត្រូវការធ្វើការរួមគ្នាជាមួយមនុស្សនៅគ្រប់កំរិតពោលគឺពីកំរិតសហគមន៏ដល់កំរិតអ្នកធ្វើគោលនយោបាយ។ អង្គការន័រវេស្ស៊ែសង្គ្រោះកុមារកម្ពុជាផ្តោតការយកចិត្តទុកដាក់លើកម្មវិធីបង្ការទប់ស្កាត់។ អ្វីដែលអាចធ្វើបានជាមួយកម្មវិធីដែលមានស្រាប់គឺព្យាយាមបញ្ចូលការអប់រំទាក់ទងនឹងការជ.ក.ផ.ក.ទៅក្នុងកម្មវិធីសិក្សា ទើបយើងអាចជួយសង្គ្រោះកុមារបានច្រើន។ ថ្មីៗនេះសម្ព័ន្ធអង្គការសង្គ្រោះកុមារបានបង្កើតក្រុមការងារមួយធ្វើការលើកិច្ចការពារកុមារ។ យើងកំពុងព្យាយាមបញ្ចូលការងារនេះទៅក្នុងកម្មវិធីនានានៃអង្គការជាសមាជិក..."។

កញ្ញា **សេន ហ្សឺន សាហ្វី** ប្រធានក្រុមជំនួយកុមារដើម្បីការរួបរួមនិងចូលរួម អាយុ១៩ឆ្នាំ

"...ការផ្តល់ឱកាសឱ្យកុមារនិងយុវជនបានចូលរួមបញ្ចេញមតិនិងក្នុងសកម្មភាពផ្សេងៗគឺមានផលប្រយោជន៏សំខាន់បំផុតពីព្រោះកុមារអាចផ្សព្វផ្សាយបន្តបានលឿននិងដឹងពីបញ្ហារបស់ក្រុមខ្លួន។ បើគ្មានការចូលរួមរបស់កុមារនិងយុវជននៅក្នុងការកសាងឬដោះស្រាយបញ្ហាសង្គម នោះគឺជាការខាតបង់មួយយ៉ាងធំ។ ក្រុមជំនួយកុមារដើម្បីការរួបរួម និងចូលរួម (CAMP) នឹងរួមសហការអនុវត្តជាមួយអង្គការទស្សនៈពិភពលោក និងក្រសួងទេសចរណ៏នូវគំរោងការមួយឈ្មោះ "ឥន្ទ្រទេវី" ដើម្បីទប់ស្កាត់ការជ.ក.ផ.ក.ទាក់ទងនឹងផ្នែកទេសចរណ៏ចាប់ពីចុងឆ្នាំ២០០១ដល់២០០៣។ ក្រុមកុមារនិងយុវជនចូលរួមកម្លាំងជាមួយមនុស្សចាស់ក្នុងគ្រប់សកម្មភាពកសាងសង្គម ប៉ុន្តែយើងខ្ញុំត្រូវការជាចាំបាច់នូវការផ្តល់ឱកាស ការលើកទឹកចិត្តនិងគំរូល្អពីមនុស្សចាស់..."។



# និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ



លោកជំទាវ **និន សាផុន** លេខាធិការគណៈកម្មការការពារសិទ្ធិមនុស្សនិងទទួលពាក្យបណ្តឹងនៃរដ្ឋសភា

"...រដ្ឋបានចេញនូវគោលនយោបាយ ច្បាប់ និងវិធានការជាច្រើនក្នុងការលើកស្ទួយសិទ្ធិមនុស្សជាពិសេសសិទ្ធិកុមារ។ ប៉ុន្តែនៅមានបញ្ហាជាច្រើនដែលយើងត្រូវប្រឈមមុខ ក្នុងនោះអំពើហិង្សាលើកុមារ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ កំពុងតែជាបញ្ហាយ៉ាងធ្ងន់ធ្ងរ។ រដ្ឋសភាបានអនុម័តច្បាប់ស្តីអំពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ហើយច្បាប់នេះកំពុងត្រូវបានអនុវត្តយ៉ាងយកចិត្តទុកដាក់។ វិធានការដ៏ក្តៅគគុកមួយទៀតនោះគឺរាជរដ្ឋាភិបាលបានដាក់បញ្ជាឱ្យបិទបណ្តាក្លឹបរាត្រី ខារ៉ាអូខេ ដែលជាប្រភពនៃអំពើហិង្សា ការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រីនិងកុមារ។ ទាំងផ្នែកនីតិបញ្ញត្តិ និងនីតិប្រតិបត្តិយើងមានឆន្ទៈនយោបាយក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ ប៉ុន្តែយើងនៅខ្វះមធ្យោបាយសំរាប់អនុវត្តអោយមានប្រសិទ្ធភាព។ យើងស្វាគមន៍រាល់ការឧបត្ថម្ភគាំទ្រពីសំណាក់សហគមន៍អន្តរជាតិក្នុងការលើកស្ទួយសិទ្ធិកុមារនិងលុបបំបាត់រាល់ការធ្វើអាជីវកម្មលើកុមារតាមគ្រប់រូបភាព..."។

លោក **លី្វ ហ្សេគហ្ស៍ អាសឺណូល** ប្រធានអង្គការយូនីសេហ្វ

"...ខ្ញុំថាបញ្ហានេះមានសភាពធ្ងន់ធ្ងរណាស់ពោលគឺមិនបានធូរស្រាលឡើយ។ យើងក៏សង្កេតឃើញមានវិធានការជាច្រើនត្រូវបានដាក់ចុះនិងប្រតិបត្តិ។ យើងមិនត្រូវយកកុមារមកពាក់ព័ន្ធនឹងបញ្ហាអាជីវកម្មផ្លូវភេទឡើយ។ នេះគឺជាអំពើដ៏គួរអោយខ្មាស់អៀនសំរាប់មនុស្សជាតិទាំងមូល។ យើងមិនត្រូវអត់ឱនអោយចំពោះអំពើនេះឡើយ ទាំងនៅកម្ពុជានិងលើពិភពលោកទាំងមូល។ ខ្ញុំយល់ថាយើងត្រូវពិនិត្យលើបញ្ហាទាំងមូលហើយរំលំពីឫសគល់នៃបញ្ហានោះ រួមមានតំរូវការនៃការរួមភេទជាមួយកុមារ និងភាពក្រីក្រ។ យើងក៏ត្រូវពិនិត្យផងដែរលើរចនាសម្ព័ន្ធតតិយុត្តិ ការផ្តល់ការគាំទ្រផ្នែកច្បាប់ដើម្បីការពារកុមារនិងនាំជនល្មើសមកកាត់ទោសជាដើម ហើយវាចាំបាច់នឹងនិយាយអំពីការផ្តល់ពត៌មានលើកកំពស់ការយល់ដឹងដល់ប្រជាជននៅតាមសហគមន៍ ជាពិសេសឪពុកម្តាយនិងកុមារ។ ខ្ញុំចង់ឃើញក្មេងជំនាន់ក្រោយមានលទ្ធភាពអាចឆ្លងផុតពីបឋមសិក្សាទៅអនុវិទ្យាល័យមានន័យថាទទួលបានការអប់រំជាមូលដ្ឋានអប្បបរមា៩ឆ្នាំឬលើសពីនេះគឺជាការប្រសើរ។ ខ្ញុំបានដឹងថាមានកុមារជាច្រើនដែលត្រូវបានគេបោកប្រាស់យកមកធ្វើជាពេស្យាចារ។ រឿងបែបនេះនឹងមិនកើតមានឡើងទេ ប្រសិនបើពួកគេទទួលបានការអប់រំល្អ។ ដូច្នេះយើងត្រូវតែធានាគុណភាពនៃការអប់រំ ជាពិសេសសំរាប់កុមារី។ ចំពោះអង្គការយូនីសេហ្វ ការប្រឆាំងនឹងការជ.ក.ផ.ក.គឺជាអាទិភាពចំបង។ នៅក្នុងយុទ្ធសាស្ត្ររួមថ្មីរបស់យើងដែលទើបត្រូវបានអនុម័តការការពារកុមារគឺជាអាទិភាពមួយក្នុងចំណោមអាទិភាពសំខាន់ទាំងប្រាំ..."។





កុមារា **ឯម ចន្ទ័មករា** ប្រធានគណៈកម្មាធិការកុមារ អាយុ១៧ឆ្នាំ

ការជ.ក.ផ.ក.មានការកើនឡើងដែលអាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការត្រួតពិនិត្យបញ្ហានេះឱ្យបានហ្មត់ចត់បំផុត។ ដោយឡែកសាលារៀននីមួយៗត្រូវពង្រឹងវិន័យសិស្សអោយបានហ្មឹងម៉ាត់ ជាពិសេសអវត្តមានប្រចាំថ្ងៃរបស់សិស្សដោយគ្មានមូលហេតុច្បាស់លាស់ដើម្បីទប់ស្កាត់កុំឱ្យសិស្សគេចសាលារៀនដែលពេលខ្លះជាហេតុនាំឱ្យទៅប្រកបរបរជាពេស្យាចារ។ ចំណុចដែលរាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់មួយទៀតនោះគឺត្រូវត្រួតពិនិត្យឱ្យបានតឹងរ៉ឹងការចេញចូលតាមច្រកព្រំដែនដែលជាផ្លូវសំរាប់ការជួញដូរកុមារឆ្លងប្រទេស។ គណៈកម្មាធិការកុមារមានឆន្ទៈមោះមុតគាំទ្រការបញ្ឈប់ជាបន្ទាន់ការជ.ក.ផ.ក.នៅកម្ពុជាដោយចូលរួមតាមរយៈការផ្សព្វផ្សាយអំពីសិទ្ធិកុមារតាមការប្រគុំតន្ត្រីការបើកសិក្ខាសាលារួមជាមួយបណ្តាញការងារកុមារនិងយុវជនទាំងនៅទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន..."។

## អនុសាសន៍របស់គណៈកម្មាធិការអង្គការសហប្រជាជាតិដើម្បីសិទ្ធិកុមារ

គណៈកម្មាធិការអង្គការសហប្រជាជាតិដើម្បីសិទ្ធិកុមារដែលមានការិយាល័យនៅទីក្រុងហ្សឺណែវ បានផ្តល់អនុសាសន៍ទាក់ទងនឹងការកេងប្រវ័ញ្ច និងជួញដូរផ្លូវភេទជូនរាជរដ្ឋាភិបាលកម្ពុជាដោយស្នើសុំអោយ:

- ពិនិត្យមើលច្បាប់របស់ខ្លួនឡើងវិញដើម្បីពង្រឹងច្បាប់នោះ ហើយទន្ទឹមនោះជំរុញអោយអនុវត្តបានពេញលេញច្បាប់បច្ចុប្បន្នដែលប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទ និងផ្តន្ទាទោសជនល្មើស។
- អនុវត្តយ៉ាងពេញលេញនូវផែនការជាតិ៥ឆ្នាំដោយបែងចែកទុកនូវធនធានហិរញ្ញវត្ថុ និងធនធានមនុស្សអោយបានគ្រប់គ្រាន់សំរាប់ការងារនេះ។
- ពង្រឹង ពង្រីកសេវាសង្គមសំរាប់ស្តារនីតិសម្បទាកុមាររងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទ។
- ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ជាពិសេសជាមួយប្រទេសជិតខាង និងបង្កើនការត្រួតពិនិត្យតាមព្រំដែន។
- ស្វែងរកជាបន្តទៅទៀតនូវជំនួយបច្ចេកទេសពីបណ្តាអង្គការនានា ដែលក្នុងនោះមានដូចជា ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការយូនីសេហ្វជាដើម។

# ៦

# អនុសាសន៍សំរាប់អនុវត្តបន្ត

## ការអំពាវនាវរបស់ឯ.ឧ. សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

(ក្នុងឱកាសបិទវគ្គសិក្ខាសាលាជាតិស្តីពីការអនុវត្តន៍ផែនការជាតិប្រឆាំងការជ.ក.ផ.ក. កាលពីថ្ងៃទី១០តុលា២០០១)

យើងបានដឹងហើយថាការតស៊ូនិងការសំរបសំរួលគឺជាកត្តាកំណត់នូវជ័យជំនះ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមធ្វើការអំពាវនាវដូចតទៅ:

- ក្រសួង មន្ទីរ និងអ្នកធ្វើការងារពាក់ពន្ធ័ ត្រូវមានការសំរបសំរួលល្អ ហើយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារត្រូវមានតួនាទីជាអ្នកសំរបសំរួលនិងពង្រឹងយន្តការត្រួតពិនិត្យអោយបានល្អ។
- គប្បីបង្កើតទីកន្លែងទទួលពាក្យបណ្តឹងប្រឆាំងការជួញដូរស្ត្រីនិងការរំលោភកុមារ ព្រមទាំងក្រុមអ្នកច្បាប់សំរាប់ការពារជនរងគ្រោះ។
- លើកទឹកចិត្តនិងជំរុញអោយស្ត្រី កុមាររងគ្រោះ ព្រមទាំងគ្រួសាររួមសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីស្វែងរកចុងចោទ និងដាក់ពាក្យបណ្តឹង។
- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពង្រឹងកម្មវិធីសិក្សាស្តីពីសិទ្ធិកុមារអោយបានកាន់តែប្រសើរឡើង។
- សហជីពកម្មករនៅតាមក្រុមហ៊ុន និងរោងចក្រនានាត្រូវអប់រំកម្មករអំពីសេរីភាព និងផលវិបាកកើតចេញពីការរួមភេទ និងអ្វីដែលគេអាចនឹងជួបប្រទះ។
- ក្រុមប្រឹក្សាតុលាការនៃទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវប្រឹងប្រែងរកកិច្ចសហការក្នុងការធ្វើពង្រាងច្បាប់ទាក់ទងនឹងសិទ្ធិកុមារ។



# អនុសាសន៍សំរាប់អនុវត្តបន្ត

អនុសាសន៍ពីកុមារនិងយុវជនមានសារៈសំខាន់និងចាំបាច់ហើយអនុសាសន៍ខាងក្រោមនេះ បានមកពីការពិភាក្សាក្នុងវគ្គសិក្ខាសាលា និងការពិគ្រោះយោបល់នានារវាងបណ្តាអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងស្ថាប័នរដ្ឋាភិបាលមួយចំនួន។ អនុសាសន៍ទាំងនេះអាចអនុវត្តទៅបានប្រកបដោយប្រសិទ្ធភាព ចំបាច់ត្រូវមានឆន្ទៈនយោបាយដោយផ្តល់អាទិភាពខ្ពស់លើការប្រយុទ្ធប្រឆាំងនឹងបញ្ហាជ.ក.ផ.ក.នេះរួមមានការផ្តល់ធនធានសមស្របទាំងធនធានថវិកា និងធនធានមនុស្សក៏ដូចជាការប្តេជ្ញាចិត្តផ្នែកគោលនយោបាយ និងការអនុវត្តន៍ជាក់ស្តែង។ លើសពីនេះទៅទៀត ដោយសារបញ្ហាជ.ក.ផ.ក.នេះជាបញ្ហាសកល កិច្ចសហប្រតិបត្តិការដ៏ស្អិតរមួតរវាងបណ្តាប្រទេសក្នុងតំបន់ និងនៅលើពិភពលោកក៏ដូចជាកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ផ្នែកឯកជន សហគមន៍ និងជាពិសេសកុមារដែលជាអ្នកដឹងច្បាស់ជាងគេនូវបញ្ហា និងតំរូវការពិតៗរបស់ខ្លួន គឺជាកត្តាគន្លឹះឈានទៅរកការលុបបំបាត់ទាំងស្រុងនូវការជ.ក.ផ.ក.ដែលជាការរំលោភសិទ្ធិកុមារនិងមិនអាចលើកលែងបាន។

## ក. ការបង្ការទប់ស្កាត់

### រាជរដ្ឋាភិបាល

- បង្កើនការអប់រំ និងផ្សព្វផ្សាយអោយបានទូលំទូលាយនូវពត៏មានទាក់ទងនឹងការជ.ក.ផ.ក. ដូចជាច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្សនិងអំពើធ្វើអាជីវកម្មលើមនុស្ស សិទ្ធិកុមារ ល្បិចកលរបស់ជនល្មើសផលប៉ះពាល់ពីការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារទៅលើកុមារដល់សហគមន៍និងអ្នកផ្តល់សេវាទេសចរណ៍តាមរយៈសិក្ខាសាលាសំរាប់មន្ត្រីពាក់ព័ន្ធ និងប្រព័ន្ធផ្សព្វផ្សាយនានា។ សហការជាមួយសេវាឯកជនក្នុងការបញ្ចូលឈុតអប់រំខ្លីៗក្នុងកម្មវិធីវិទ្យុ ទូរទស្សន៍ ខ្សែភាពយន្ត វីដេអូ និងជំរុញអោយក្រសួងធម្មការនិងកិច្ចការសាសនាចូលរួមផ្សព្វផ្សាយតាមពិធីបុណ្យនានា និងវត្តអារាម។
- ជំរុញ និងបង្កលក្ខណៈអោយកុមារបានចូលរៀនគ្រប់ៗគ្នា និងបង្កើនការអប់រំអំពីអនុសញ្ញាស្តីពីសិទ្ធិកុមារ បញ្ហាពាក់ព័ន្ធនឹងការជ.ក.ផ.ក. ជំងឺអេដស៍ ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន សុខភាពបន្តពូជទៅក្នុងកម្មវិធីអប់រំក្នុងនិងក្រៅប្រព័ន្ធ។

- ពង្រឹងនិងពង្រីកបណ្តាញការពារកុមារនៅតាមភូមិ និងរៀបចំអោយមានបណ្តាញការងារពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋានក្នុងការទទួលនិងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការជ.ក.ផ.ក.អោយទាន់ពេលវេលា និងធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយពីយន្តការនេះ។
- ពង្រឹងមន្ត្រីអត្រានុកូលដ្ឋាន និងបង្កើនការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការធ្វើសំបុត្រកំណើត ក៏ដូចជាជំរុញអោយមានការចុះបញ្ជីជាតិកុមារគ្រប់ៗគ្នា។
- ពង្រឹងនិងលើកស្ទួយបន្ថែមនូវវប្បធម៌ជាតិ និងចាត់វិធានការអោយបានម៉ឺងម៉ាត់ដើម្បីត្រួតពិនិត្យលំហូរចូលនៃវប្បធម៌ពីបរទេស ដែលប្រឆាំងនឹងទំនៀមទំលាប់ និងប្រពៃណីជាតិខ្មែរ។
- ធ្វើអោយប្រសើរឡើងនូវកម្មវិធីកាត់បន្ថយភាពក្រីក្រតាមរយៈការផ្តល់ទុន ជំនាញវិជ្ជាជីវៈ និងកម្មវិធីសន្តិសុខស្បៀង។

## អង្គការមិនមែនរដ្ឋាភិបាល

- ពង្រីកកម្មវិធីបង្ការ និងទប់ស្កាត់អោយបានទូលំទូលាយ ដោយបំផុសអោយមានការចូលរួម និងការទទួលខុសត្រូវពីបណ្តាញសារព័ត៌មាននានា សហគមន៍ និងវត្តអារាម។ បង្កើនការផលិតសំភារៈផ្សព្វផ្សាយ ដូចជាឯកសារខ្លីៗ ឈុតវីដេអូខ្លីៗ ផ្ទាំងរូបភាព ដោយត្រួតពិនិត្យខ្លឹមសាររូបភាពអោយបានត្រឹមត្រូវ ព្រមទាំងចែកផ្សាយអោយបានដល់មូលដ្ឋានដាច់ស្រយាល។
- ពង្រឹងនិងពង្រីកក្រុមកុមារជួយកុមារដើម្បីរួមចំណែកក្នុងការទប់ស្កាត់ និងការពារកុមារពីការជ.ក.ផ.ក.ជាពិសេសក្នុងតំបន់មុខសញ្ញានិងតំបន់ងាយរងគ្រោះ។
- ធ្វើការសិក្សាស្រាវជ្រាវដោយរកអោយឃើញស្ថិតិជាក់ស្តែងនៃការជ.ក.ផ.ក.នៅប្រទេសកម្ពុជា និងធ្វើការតាមដានបន្តពីការវិវត្តន៍នៃសភាពការណ៍នៅក្នុងសហគមន៍អោយបានទៀងទាត់។
- សហការជាមួយរាជរដ្ឋាភិបាល ជាពិសេសក្រសួងអភិវឌ្ឍន៍ជនបទនិងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាក្នុងការអភិវឌ្ឍន៍កម្មវិធីបង្កើនចំណូលគ្រួសារពិសេសនៅតាមជនបទដាច់ស្រយាល តាមរយៈការផ្តល់ជំនាញវិជ្ជាជីវៈ និងទុន។

## សហគមន៍

- អាជ្ញាធរមូលដ្ឋានត្រូវស្រង់ស្ថិតិកុមារអោយបានច្បាស់លាស់ទៅតាមប្រភេទនៃបញ្ហារបស់គេ និងត្រូវផ្សព្វផ្សាយអោយកុមារនៅក្នុងភូមិបានយល់ដឹងពីមុខសញ្ញាគ្រោះថ្នាក់ ល្បិចកលរបស់ជនខិលខូច និងវិធីសាស្ត្រការពារខ្លួន។



- ឪពុកម្ដាយត្រូវលះបង់គំនិតបង្ខំកូនអោយចេញរកលុយដើម្បីជួយដោះស្រាយបន្ទុកគ្រួសារ ត្រូវអប់រំទូន្មានកូនរបស់ខ្លួន និងចេះរាយការណ៍ដល់អាជ្ញាធរពីជនសង្ស័យ និងបញ្ហាពាក់ព័ន្ធនឹងការជ.ក.ផ.ក. ដែលបំរុងនឹងកើតមានក្នុងសហគមន៍របស់ខ្លួន ដើម្បីអោយអាជ្ញាធរមូលដ្ឋានចាត់វិធានការទាន់ពេលវេលា។
- ពង្រឹងនិងពង្រីកក្រុមការងារដូចជាគណៈកម្មការអភិវឌ្ឍន៍ភូមិ សមាគមមាតាបិតា និងក្រុមកុមារជួយកុមារដើម្បីការពារសុវត្ថិភាពកុមារក្នុងសហគមន៍។

### ផ្នែកឯកជន

- គោរពនិងអនុវត្តច្បាប់ សេចក្ដីប្រកាស សារាចរ អោយមានប្រសិទ្ធភាពខ្ពស់ ជាពិសេសច្បាប់ប្រទេសកម្ពុជាទាក់ទងការនាំចូលនូវផលិតផល និងវប្បធម៌បរទេសដែលជះឥទ្ធិពលមិនល្អឬប្រឆាំងវប្បធម៌ប្រពៃណីជាតិខ្មែរ។
- ផ្សព្វផ្សាយដល់បុគ្គលិកក្នុងស្ថាប័នរបស់ខ្លួនអោយមានការយល់ដឹង និងចូលរួមក្នុងការទប់ស្កាត់អំពើជ.ក.ផ.ក. និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរនៅពេលឃើញរាល់ហេតុការណ៍សង្ស័យ។
- សារព័ត៌មាន វិទ្យុ ទូរទស្សន៍ឯកជន ត្រូវចូលរួមអោយបានច្រើនក្នុងការផ្សព្វផ្សាយអំពីការការពារ និងការជួញដូរកុមារ និងគោរពសិទ្ធិឯកជនរបស់កុមារ។
- សេវាឯកជននានា ជាពិសេសសេវាទេសចរណ៍ត្រូវចេញគោលការណ៍ហាមឃាត់ការជ.ក.ផ.ក. និង បិទផ្សាយខិត្តប័ណ្ណ ផ្ទាំងរូបភាព ផ្លាកសញ្ញា បដា ប៉ាណូ ។ល។ ស្ដីពីការប្រឆាំងការជ.ក.ផ.ក. នៅតាមការិយាល័យ សណ្ឋាគារ បនពេស្យា។ល។

## ខ. ការការពារ

### រាជរដ្ឋាភិបាល

- ផ្ដល់សច្ចាប័ន និងអនុវត្តអោយមានប្រសិទ្ធភាពលើឯកសារគតិយុត្តិអន្តរជាតិដូចជាអនុសញ្ញាILO លេខ១៨២ស្ដីពីការហាមឃាត់និងលុបបំបាត់ជាបន្ទាន់រាល់ទំរង់ពលកម្មធ្ងន់ធ្ងរលើកុមារ ពិធីសារបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ស្ដីពីការជួញដូរកុមារ ពេស្យាចារកុមារ និងអំពើកាមសាស្ត្រលើកុមារ និងពិធីសារបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងប្រទេសស្ដីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មទៅលើការជួញដូរមនុស្សជាពិសេសទៅលើស្ត្រី និងកុមារ។

- អនុវត្តអោយមានប្រសិទ្ធភាពនូវអនុសាសន៍របស់គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារលើបញ្ហាជ.ក.ផ.ក. ។
- គាក់តែងច្បាប់ដោយឡែកសំរាប់កុមារអោយស្របតាមអនុសញ្ញាសិទ្ធិកុមារ ព្រមទាំងពង្រឹងការអនុវត្តន៍ច្បាប់អោយមានប្រសិទ្ធភាព និងផ្តន្ទាទោសជនល្មើសដោយមិនរើសមុខ ។
- ធ្វើវិសោធនកម្មច្បាប់បង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្សដោយកំនត់អោយបានច្បាស់លាស់នូវអាយុអាចយល់ព្រមរួមភេទបាន និងបញ្ចូលនូវការកំណត់ទោសដល់ជនដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មលើកុមារក្នុងការផលិតសំភារៈអាសគ្រោស ។
- បង្កើនការបើកវគ្គបណ្តុះបណ្តាលពីអនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់ពាក់ព័ន្ធដល់ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីអនុវត្តច្បាប់ មេធាវី អោយបានច្រើនដើម្បីពង្រឹងសមត្ថភាព និងតួនាទីក្នុងការងារប្រយុទ្ធប្រឆាំងការជ.ក.ផ.ក. ។
- បង្កើតកន្លែងទទួលពាក្យបណ្តឹងដាច់ដោយឡែកសំរាប់កុមារ និងមានមេធាវី ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីអនុវត្តច្បាប់ដែលមានជំនាញខាងដោះស្រាយរឿងក្តីកុមារ ។
- បង្កើតបណ្តាញទូរស័ព្ទពិសេសប្រចាំការ២៤ម៉ោងនៅគ្រប់បណ្តាខេត្តនានានៅទូទាំងប្រទេសសំរាប់ទទួលពត៌មាននិងស្នើសុំជំនួយពេលជួបបញ្ហាការរំលោភសិទ្ធិកុមារ ជាពិសេសការជ.ក.ផ.ក. ។ ផ្សព្វផ្សាយអោយបានទូលំទូលាយពីសេវានេះទៅដល់ប្រជាជន ព្រមទាំងបង្កើតអោយមានយន្តការគាំទ្រ និងការពារកុមាររងគ្រោះ កុមារជាសាក្សី និងជនដែលរាយការណ៍ពីបញ្ហាជ.ក.ផ.ក.ដល់អាជ្ញធរ ។
- បង្កើនចំនួនស្ត្រីជាមន្ត្រីអនុវត្តច្បាប់អោយបានច្រើន និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នអនុវត្តច្បាប់អោយមានប្រសិទ្ធភាព ។
- ពង្រឹងការត្រួតពិនិត្យតាមដានផ្ទះបន កន្លែងម៉ាស្សា ខារ៉ាអូខេ ។ល។ ដែលមានការសង្ស័យថាមានធ្វើអាជីវកម្មផ្លូវភេទលើកុមារ ។
- សហការជាមួយប្រទេសជិតខាងដើម្បីចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការលុបបំបាត់ការនាំចូលនូវវីដេអូ រូបភាពអាសអាភាសនិងគ្រឿងញៀនដែលជាកត្តាជំរុញអោយមានការជ.ក.ផ.ក.និងភាពអានាចារក្នុងសង្គម ។



### អង្គការមិនមែនរដ្ឋាភិបាល

- បង្កើនបណ្តាញការពារកុមារអោយដល់តំបន់ដាច់ស្រយាលទូទាំងប្រទេសដោយធ្វើការសហការយ៉ាងជិតស្និទជាមួយអាជ្ញាធរមូលដ្ឋាន។
- បង្កើនការផ្សព្វផ្សាយពីច្បាប់ពាក់ពន្ធ័អោយបានទូលំទូលាយដល់មន្ត្រីអនុវត្តច្បាប់និងសហគមន៍ និងបង្កើនការផ្តល់ជំនួយផ្នែកច្បាប់ដល់កុមាររងគ្រោះដោយឥតគិតថ្លៃ។
- ពង្រឹងគណៈកម្មការនីតិកម្មក្នុងការសិក្សាស្រាវជ្រាវ ពិនិត្យពង្រាងច្បាប់ដែលទាក់ទងនឹងកុមារដើម្បីលើកជាសំណើនិងអនុសាសន៍ដាក់ជូនរាជរដ្ឋាភិបាល។
- ពង្រឹងឬបង្កើតគណៈកម្មាធិការមួយដែលមានយុទ្ធសាស្រ្ត ប្រភពធនធាន ផែនការច្បាស់លាស់សំរាប់ធ្វើការតស៊ូមតិ ការពារ និងទប់ស្កាត់ការជ.ក.ផ.ក.។

### សហគមន៍

- មេឃុំ ចៅសង្កាត់ និងមន្ត្រីមូលដ្ឋានត្រូវសិក្សាស្វែងយល់ពីអនុសញ្ញាសិទ្ធិកុមារ និងច្បាប់ពាក់ពន្ធ័ផ្សេងៗ ជាពិសេសច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្សនិងអំពើធ្វើអាជីវកម្មលើមនុស្ស និងចាត់វិធានការតឹងរ៉ឹងដើម្បីលុបបំបាត់ការបញ្ជាំងវីដេអូអាសអាភាស ផ្ទះបន និងបនល្បែងស៊ីសង។
- បង្កើតអោយមានយន្តការក្នុងការទទួលពាក្យបណ្តឹង និងដោះស្រាយពាក្យបណ្តឹងអោយទាន់ពេល និងបំផុសប្រជាជនអោយចេះការពារខ្លួន មិនលាក់ពត៌មាន និងហ៊ានប្តឹង។

### ផ្នែកឯកជន

- ចូលរួមផ្តល់ពត៌មាន និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការជួយសង្គ្រោះកុមាររងគ្រោះនិងចាប់ខ្លួនជនល្មើស។
- ម្ចាស់សេវាខារ៉ាអូខេ ម៉ាស្សា ។ល។ មិនត្រូវបង្ខំក្មេងអាយុក្រោម១៨ឆ្នាំអោយបំរើផ្លូវភេទទេ។

## គ. ការស្តារនិងអភិវឌ្ឍន៍សមត្ថភាព

### រាជរដ្ឋាភិបាល

- បង្កើនចំនួនមជ្ឈមណ្ឌលស្តារនីតិសម្បទា និងមណ្ឌលសំចតសំរាប់កុមាររងគ្រោះ នៅតាមតំបន់ដែលមានបញ្ហា ព្រមទាំងបង្កើតមជ្ឈមណ្ឌលសំរាប់ថែទាំកុមារដែលផ្ទុកមេរោគអេដស៏ និងកើតជំងឺអេដស៏។

- ពង្រឹងនិងពង្រីកការបណ្តុះបណ្តាលមន្ត្រីធ្វើការងារផ្នែកបំប៉នបំនិនជីវិត ការពិគ្រោះយោបល់ និងចិត្តសាស្ត្រកុមារ។
- ធ្វើបញ្ជីអង្គការស្ថាប័នផ្តល់សេវាដល់កុមាររងគ្រោះនិងផ្សព្វផ្សាយពីសេវានេះអោយបានទូលំទូលាយ។
- ពង្រឹងកិច្ចសហការជាមួយសេវាឯកជនក្នុងការផ្តល់ជំនាញវិជ្ជាជីវៈសមស្របទៅនឹងតំរូវការទីផ្សារ និងសហគមន៍ដល់កុមារ។
- បែងចែកថវិកាសមស្របសំរាប់កម្មវិធីស្តារនីតិសម្បទា និងសេវាទ្រទ្រង់កុមាររងគ្រោះ ព្រមទាំងផ្តល់សេវាសុខភាពដោយឥតបង់ថ្លៃ។

## អង្គការមិនមែនរដ្ឋាភិបាល

- បង្កើនមណ្ឌលសំរាប់កុមាររងគ្រោះក្នុងការស្នាក់នៅបណ្តោះអាសន្ន ព្រមទាំងសហការជាមួយរដ្ឋាភិបាលក្នុងការបណ្តុះបណ្តាលធនធានមនុស្សសំរាប់ការងារស្តារនិងអភិវឌ្ឍន៍សមត្ថភាពកុមាររងគ្រោះ។
- ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈសមស្របដល់កុមាររងគ្រោះដោយមានការសិក្សាល្អិតល្អន់ជាមុនពីតំរូវការទីផ្សារដោយផ្សារភ្ជាប់ទៅនឹងមូលដ្ឋាន។

## សហគមន៍

- គាំទ្រ លើកទឹកចិត្តដល់កុមាររងគ្រោះ និងសហការជាមួយម្ចាស់កម្មវិធីក្នុងការផ្តល់ពត៌មានពាក់ព័ន្ធ និងចូលរួមក្នុងការចែករំលែកបន្តនូវបទពិសោធន៍ ជំនាញ និងបំនិនជីវិត។

## ផ្នែកឯកជន

- សហការ និងគាំទ្រដល់កម្មវិធីស្តារនិងអភិវឌ្ឍន៍សមត្ថភាពកុមាររងគ្រោះ ជាស្មារតី សំភារៈ ថវិកា។

# ឃ. សមាហរណកម្ម

## រាជរដ្ឋាភិបាល

- ពង្រឹងសមត្ថភាពនិងតួនាទីរបស់មន្ត្រីសង្គមកិច្ច អាជ្ញាធរមូលដ្ឋាន និងសហគមន៍រួមមាន គ្រូបង្រៀន ព្រះសង្ឃ និងគណៈកម្មការអភិវឌ្ឍន៍ភូមិ។ល។ ក្នុងការទ្រទ្រង់ និងតាមដានសុខុមាលភាព និងសុវត្ថិភាពរបស់កុមារ ដែលបានធ្វើសមាហរណកម្ម ព្រមទាំងផ្តល់ពត៌មានដល់អង្គការ ឬស្ថាប័នពាក់ព័ន្ធក្នុងករណីមានបញ្ហា។



- រៀបចំអនុស្សរណៈនៃការយោគយល់គ្នារវាងប្រទេសនិងប្រទេសដើម្បីសំរួលដល់ការធ្វើសមាហរណកម្មឆ្លងប្រទេស។ ក្នុងករណីនេះ រដ្ឋាភិបាលនៃប្រទេសពាក់ពន្ធ័ត្រូវរៀបចំមណ្ឌលស្នាក់នៅបណ្តោះអាសន្នមុនពេលធ្វើសមាហរណកម្មមកប្រទេសដើមវិញអោយបានត្រឹមត្រូវដោយដាក់កុមារផ្សេងពីអ្នកទោសដទៃ ព្រមទាំងផ្តល់សេវាសុខភាព ពិគ្រោះយោបល់។ល។
- ធ្វើការកោះប្រជុំដល់សេវាឯកជនដើម្បីរកការងារ និងជួយសំរួលលក្ខខ័ណ្ឌការងារកុមារមុខសញ្ញានិងជំរុញអោយសេវាឯកជនគោរព និងអនុវត្តច្បាប់ សេចក្តីប្រកាស និងសារាចរដែលពាក់ព័ន្ធផ្សេងៗ។

## អង្គការមិនមែនរដ្ឋាភិបាល

- បង្កើតនិងពង្រឹងបណ្តាញការងារសហគមន៍ដើម្បីការពារ និងតាមដានការវិវត្តន៍របស់កុមាររងគ្រោះដោយសហការជាមួយអាជ្ញាធរ។
- លុបបំបាត់ភាពរើសអើង តាមរយៈការអប់រំដល់គ្រួសារ និងសហគមន៍អំពីការជ.ក.ផ.ក. និងផលប៉ះពាល់លើកុមារ ដោយធ្វើអោយសហគមន៍យល់ថាបញ្ហានេះមិនមែនជាកំហុសរបស់កុមាររងគ្រោះទេ។

## សហគមន៍

- បង្កើតអោយមានជាមូលនិធិសំរាប់សហគមន៍និងទ្រទ្រង់កុមាររងគ្រោះ តាមរយៈការរៃអង្គាសប្រាក់។
- ត្រូវទទួលស្គាល់និងយកចិត្តទុកដាក់តាមដានកុមារដែលធ្វើសមាហរណកម្ម ដោយធានាមិនអោយមានការរើសអើង ឬការប្រមាថមើលងាយចំពោះកុមារឡើយ។
- មនុស្សសំខាន់ក្នុងភូមិដូចជាព្រះសង្ឃ អាចារ្យ ចាស់ព្រឹទ្ធាចារ្យ ត្រូវចូលរួមក្នុងការការពារកុមារមុខសញ្ញា និងគ្រួសារ ព្រមទាំងសហគមន៍ទាំងមូល។

## ផ្នែកឯកជន

- បង្កើតរោងចក្រ សហគ្រាស នៅតាមបណ្តាខេត្ត ដោយមិនផ្តុំតែនៅទីក្រុង។
- រកទីផ្សារសំរាប់ផលិតផលកសិកម្ម និងអោយមានតំលៃសមរម្យ។
- គោរព និងអនុវត្តច្បាប់ការងារ ហើយផ្តល់ការងារនិងបៀវត្សរ៍សមស្របដល់កុមារ។

## ង. កិច្ចសំរបសំរួលនិងសហប្រតិបត្តិការ

- ពង្រឹងនិងពង្រីកយន្តការសំរបសំរួល និងតាមដានការអនុវត្តន៍ផែនការជាតិ៥ឆ្នាំប្រឆាំងការជ.ក.ផ.ក. នៅថ្នាក់ជាតិ ខេត្ត និងមូលដ្ឋាន។ ផ្តល់ធនធានសមស្របរួមមានធនធានមនុស្សនិងថវិកា ដើម្បីដំណើរការយន្តការនេះ ព្រមទាំងជំរុញអោយមានការចូលរួមសហការយ៉ាងសកម្មពីសំណាក់ស្ថាប័នរដ្ឋពាក់ពន្ធ័ អាជ្ញាធរមូលដ្ឋាន អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងកុមារ។
- ពង្រឹងការផ្លាស់ប្តូរពត៌មាន និងបទពិសោធន៍ តាមរយៈការប្រជុំជាប្រចាំរវាងស្ថាប័នរដ្ឋ អង្គការជាតិ អន្តរជាតិ និងម្ចាស់ជំនួយដែលធ្វើការពាក់ពន្ធ័លើបញ្ហានេះ តាមរយៈការបើកសិក្ខាសាលានៅថ្នាក់ខេត្ត និងថ្នាក់ជាតិជារៀងរាល់ឆ្នាំ។
- សហការរវាងអង្គការមិនមែនរដ្ឋាភិបាលនិងរាជរដ្ឋាភិបាលក្នុងការកំនត់តំបន់អនុវត្តគំរោងអោយចំទិស។
- ពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងអន្តរជាតិក្នុងការបង្ក្រាបជនល្មើស និងជួយសង្គ្រោះកុមាររងគ្រោះតាមរយៈការផ្លាស់ប្តូរពត៌មាននិងបទពិសោធន៍។ បង្កើតអនុស្សរណៈនៃការយោគយល់គ្នា និងការធ្វើបត្យាប័ន។

## ច. ស្ថាប័នខាងក្រៅពាក់ព័ន្ធការអភិវឌ្ឍន៍ប្រទេសកម្ពុជា

- ចំពោះជំនួយអភិវឌ្ឍន៍ទ្វេភាគីដែលមានគោលបំណងពង្រឹងអភិបាលកិច្ចល្អ គួរបញ្ចូលជំនួយដល់រាជរដ្ឋាភិបាលកម្ពុជាលើវិធានការទប់ស្កាត់និងការពារ ដូចដែលបានលើកឡើងក្នុងរបាយការណ៍នេះ។
- ចំពោះជំនួយទ្វេភាគីសំរាប់ទ្រទ្រង់កិច្ចផ្តួចផ្តើមនៃសង្គមស៊ីវិល គួរបញ្ចូលវិធានការនានាដើម្បីលើកកំពស់ការចូលរួមរបស់យុវវ័យនៅតាមសហគមន៍ និងបង្កើតគណៈកម្មការការពារកុមារនៅថ្នាក់មូលដ្ឋាន។
- ចំពោះភ្នាក់ងារពហុភាគីដែលរួមចំណែកអភិវឌ្ឍន៍កម្ពុជា ជាពិសេសធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក គួរបញ្ចូលការឆ្លើយតបទៅនឹងការព្រួយបារម្ភដែលបានលើកឡើងក្នុងរបាយការណ៍នេះជាចំនុចសកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ខ្លួន។
- ចំពោះសមាគមអាស៊ាន គួរបញ្ចូលផ្នែកផ្សេងៗដែលមាននៅក្នុងរបាយការណ៍នេះ ទៅក្នុងយុទ្ធសាស្ត្រដើម្បីជួយអភិវឌ្ឍន៍កម្ពុជាដែលជាប្រទេសសមាជិកមួយនៃសមាគមនេះ។

មិនត្រូវលើកលែងទោសដាច់ខាតចំពោះការរំលោភនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

ទោះក្នុងឱកាសណា ទីកន្លែងណា ឬក្នុងស្ថានភាពណាក៏ដោយ!

ត្រូវរួមគ្នាបញ្ឈប់ជាបន្ទាន់ការរំលោភសិទ្ធិកុមារ ដោយត្រូវប្រែក្លាយការប្ដេជ្ញាចិត្ត

អោយទៅជាការអនុវត្តន៏ជាក់ស្ដែង ហើយត្រូវចាប់ផ្ដើមនៅថ្ងៃនេះ!

ខ្លឹមសារដែលលើកឡើងនៅក្នុងសៀវភៅនេះគឺជាគំនិតរបស់អ្នកចូលរួមចងក្រងនិងមិនមែនចេញពីគោលនយោបាយនិងទស្សនៈ
របស់អង្គការយូនីសេហ្វទេ ។



ផលិតក្រោមការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីៈ

unicef

UN
Combating Trafficking
in Women and Children

Save the Children Norway
Cambodia Office